សម្ដេចនាយករដ្ឋមន្ត្រី៖ «យើងមិនអាចប្រើសង្គ្រាមដើម្បីបញ្ចប់សង្គ្រាមនោះទេ» <ទំព័រ៖៣



លោក អូលីវីយេ ៖ «អត្តសញ្ញាណបព្វជិតផ្ដល់កម្លាំងទៅប្រកាសដំណឹងល្អ» <ទំព័រ៖១៥


កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១២

# អ្នកនាំសារ the messenger

ខែ កុម្ភៈ | ឆ្នាំ ២០២២ | លេខទី ១៤៨

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ https://khmer.rvasia.org/

February, 2022 | #148


## បូជនីយចារយុវជន «តើសុភមង្គលដ៏ពិតប្រាកដជាអ្វី?»

យុវជនមកពីមណ្ឌលសកម្មភាពទាំង៩នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញចំនួន ២៣០នាក់ ដែលដឹកនាំដោយលោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ អូលីវីយេ ឆ្មីតហស្លេ រួមជាមួយក្រុមការិយាល័យយុវជន ជំទង់ កុមារ និងគ្រួសារ ធ្វើបូជនីចរទៅកាន់ភ្នំវល្លិ៍។ កម្មវិធីនេះធ្វើឡើងកាលពី ថ្ងៃទី៤ ដល់៦ ខែកុម្ភៈ ឆ្នាំ២០២២ ក្រោមប្រធានបទ "ជំនឿធ្វើឱ្យយើងទៅមុខ"។



# ២០២២ ជាឆ្នាំនៃ ក្ដីសង្ឃឹមថ្មី



ដើមឆ្នាំ ២០២២ ជាសេចក្ដីសង្ឃឹមថ្មីសម្រាប់យើងម្នាក់ៗ ក្រោយពេលបិទបញ្ចប់ព្រឹត្តិការណ៍ កូវីដ-១៩ ២០ កុម្ភៈ ឆ្លងក្នុងសហគមន៍ ។ ទោះបីជានៅមានការឆ្លងមួយចំនួនផ្សេងទៀត ដែលមានមេរោគបម្លែងថ្មីក៏ដោយ។ យើងនៅមានសង្ឃឹមថ្ងៃណាមួយ វានឹងទៅជាសភាពការណ៍ធម្មតា មិនបង្កឱ្យភ័យខ្លាច និងបង្កឱ្យរាំងស្ទះចរន្តសង្គមបន្តទៅទៀត។

ទោះបីជាការឆ្លងស្រាកស្រាន្តខ្លះក៏ដោយ ក៏យើងមិនត្រូវធ្វេសប្រហែសឡើយ ត្រូវគោរពវិធានការពារនានារបស់ក្រសួងសុខាភិបាល និងរៀនរស់ក្នុងបរិបទថ្មីនៃកូវីដ-១៩ ។

សេចក្ដីសង្ឃឹម ត្រូវតែដុះឡើង ក្នុងជម្រៅចិត្តរបស់យើងជាបុត្រធីតារបស់ព្រះជាម្ចាស់ ព្រោះព្រះអង្គប្រទានឱ្យម្នាក់ៗនូវរូបកាយអំណោយទានដ៏បរិបូរណ៍ ជាពិសេសជីវិតមានតម្លៃ។ ព្រះអង្គបានថែរក្សាយើង ការពារយើង និងបានបំភ្លឺដល់អ្នកវិទ្យាសាស្ត្រ ដើម្បីរកផ្លូវចេញពីមេរោគដ៏សាហាវនេះ គឺបានបង្កើតវ៉ាក់សាំងជាច្រើនដើម្បីប្រឆាំងមេរោគឆ្លងកូវីដ-១៩ ។ ប្រជាជនជាច្រើនក្នុងពិភពលោកបានទទួលវ៉ាក់សាំងទាំងនោះស្ទើរតែគ្រប់ៗគ្នា។

សេចក្ដីសង្ឃឹមត្រូវតែរក្សាជានិច្ចចំពោះយើងជាគ្រីស្តបរិស័ទ ជាប្រជារាស្ត្រដែលព្រះអង្គបានជ្រើសរើស ត្រូវផ្សារភ្ជាប់ជាមួយព្រះជាម្ចាស់ជានិច្ចតាមរយៈការអធិដ្ឋាន និងការស្ដាប់ព្រះបន្ទូលរបស់ព្រះយេស៊ូគ្រីស្តជាអម្ចាស់។

ទោះបីជាពិភពលោកមានព្រឹត្តិការណ៍ថ្មីៗដែលនាំឱ្យយើងភ័យខ្លាច និងវឹកវរក៏ដោយ ក្នុងនោះរួមមាន ការច្រណែន ឈ្នានីស ការឈ្លានពាន ការកាប់សម្លាប់គ្នា អ្នកមានជិះជាន់អ្នកតូចតាច មហាអំណាចគាបសង្កត់ប្រទេសតូចតាច កេងប្រវ័ញ្ចសេដ្ឋកិច្ច ដែលបង្កឱ្យប្រជារាស្ត្រជួបការលំបាក។ ព្រឹត្តិការណ៍ វិបត្តិរុស្ស៊ី និងអ៊ុយក្រែន ជាការបារម្ភមួយរបស់ពិភពលោក ដែលមហាអំណាចសព្វាវុធចេញមុខប្រឆាំងគ្នា ថ្ងៃណាមួយនឹងបាត់បង់ការគ្រប់គ្រង ដែលនាំឱ្យប្រើប្រាស់អាវុធប្រល័យលោកដោយភាគីណាមួយ។

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ ក៏បានក្រើនរំឭក និងអំពាវនាវ ឱ្យគ្រប់មេដឹកនាំយកចិត្តទុកដាក់កសាងសន្តិភាព ជាពិសេសគ្រីស្តបរិស័ទគ្រប់រូប ត្រូវយកចិត្តទុកដាក់អធិដ្ឋាន និងតមអាហារ សម្រាប់សន្តិភាពនៅអ៊ុយក្រែន ក៏ដូចជាសន្តិភាពក្នុងពិភពលោកយើងនេះ។ ក្នុងតំបន់អាស៊ី ប្រទេសមីយ៉ាន់ម៉ាក៏កំពុងជួបវិបត្តិសង្គ្រាមច្បាំងគ្នា ដែលនាំឱ្យប្រជាជនរងទុក្ខលំបាកផងដែរ។

ក្នុងលិខិតសម្រាប់រដូវអប់រំពិសេស សម្ដេចប៉ាបហ្វ្រង់ស៊ីស្កូបានលើកឡើងថា យើងមិនត្រូវនឿយណាយនឹងការអធិដ្ឋានឡើយ។ ព្រះយេស៊ូបានបង្រៀនយើងថា ត្រូវតែ«អធិដ្ឋានឥតឈប់ឈរ» (លូកា ១៨,១)។ យើងត្រូវអធិដ្ឋាន ដ្បិតយើងត្រូវការព្រះជាម្ចាស់។ ការយល់ឃើញថា ការពឹងផ្អែកតែលើកម្លាំងខ្លួនឯងគឺគ្រប់គ្រាន់ហើយ ជាការយល់ច្រឡំដ៏គ្រោះថ្នាក់។ ជំងឺរាតត្បាតបង្កផលប៉ះពាល់ឱ្យយើងទទួលស្គាល់ពីភាពទន់ខ្សោយទាំងបុគ្គល និងសង្គម ប៉ុន្តែសូមឱ្យរដូវអប់រំពិសេសនេះ ជួយយើងឱ្យមានបទពិសោធជំនឿរឹងប៉ឹងក្នុងព្រះជាម្ចាស់ ដែលជាទីពឹងរបស់យើង (អេសាយ ៧,៩)។ គ្មាននរណាម្នាក់អាចសង្គ្រោះខ្លួនឯងបានឡើយ ដ្បិតយើងទាំងអស់គ្នានៅក្នុងទូកដែលត្រូវខ្យល់ព្យុះនៃប្រវត្តិសាស្ត្រកំពុងបក់បោក។ គ្មាននរណាម្នាក់អាចសង្គ្រោះខ្លួនឯងដោយគ្មានព្រះជាម្ចាស់បានឡើយ ដ្បិតមានតែការអាថ៌កំបាំងនៃបុណ្យចម្លងរបស់ព្រះយេស៊ូគ្រីស្តប៉ុណ្ណោះ ដែលផ្ដល់ជ័យជំនះនៅលើពិភពនៃសេចក្ដីស្លាប់។ ជំនឿមិនបង្វែរទុក្ខលំបាកចេញពីជីវិតរបស់យើងទេ តែជំនឿផ្ដល់ឱ្យយើងឆ្លងកាត់ទុក្ខលំបាកទាំងនោះ ដោយរួមជាមួយព្រះជាម្ចាស់ក្នុងអង្គព្រះយេស៊ូគ្រីស្ត ដែលប្រទានឱ្យយើងមានសេចក្ដីសង្ឃឹមយ៉ាងមុតមាំ និងមិនបណ្ដោយឱ្យយើងខកចិត្តឡើយ ហើយព្រះវិញ្ញាណដ៏វិសុទ្ធក៏ចាក់បង្ហូរសេចក្ដីស្រឡាញ់មកបញ្ចាំក្នុងចិត្តរបស់យើងផងដែរ (រ៉ូម ៥,១-៥)។

យើងមិនត្រូវនឿយណាយនឹងការលុបបំបាត់អំពើអាក្រក់ចេញពីក្នុងជីវិតរបស់យើងឡើយ។ សូមឱ្យការតមអាហារខាងរូបកាយក្នុងរដូវអប់រំពិសេស ពង្រឹងស្មារតីរបស់យើងប្រឆាំងនឹងអំពើបាប។ យើងមិនត្រូវនឿយណាយនឹងការស្នើសុំការលើកលែងទោសក្នុងអគ្គសញ្ញាស្រាយបាប និងសម្រុះសម្រួលឡើយ។ យើងគប្បីដឹងថា ព្រះជាម្ចាស់មិននឿយហត់នឹងលើកលែងទោសឱ្យយើងនោះទេ។ យើងមិនត្រូវនឿយណាយប្រឆាំងនឹងកាមតណ្ហាឡើយ។ វាគឺជាភាពទន់ខ្សោយដែលជំរុញយើងឱ្យក្លាយទៅជាមនុស្សអាត្មានិយម និងប្រព្រឹត្តអំពើអាក្រក់គ្រប់យ៉ាង។ នៅគ្រប់សម័យទាំងអស់ គេសង្កេតឃើញមនុស្សមានមធ្យោបាយជាច្រើន ដែលបណ្ដាលឱ្យខ្លួនធ្លាក់ទៅក្នុងអំពើបាប (cf. Enc. Fratelli tutti, លេខ ១៦៦)។ មធ្យោបាយទាំងនោះរួមមាន ការញៀននឹងបណ្ដាញព័ត៌មានឌីជីថល ដែលញ៉ាំងឱ្យទំនាក់ទំនងរបស់មនុស្សកាន់តែខ្សោយទៅ។ រដូវអប់រំពិសេសគឺជាពេលវេលាដ៏សំខាន់ ដើម្បីប្រឆាំងរាល់ឧបសគ្គទាំងនេះ ហើយជួយឱ្យយកចិត្តទុកដាក់បង្កើតទំនាក់ទំនងទាំងស្រុងជាមួយគ្នាទៅវិញទៅមក (ឯកសារដដែល លេខ ៤៣) គឺការបង្កើតទំនាក់ទំនងជាក់ស្ដែង (ឯកសារដដែល លេខ៥០) ទល់មុខគ្នា៕

CSC
Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្ដីប្រកាសលេខ៖ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

# សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ៖ «យើងមិនអាចប្រើសង្គ្រាមដើម្បីបញ្ចប់សង្គ្រាមនោះទេ»

*អត្ថបទ៖ អមរិន្ទ ដានុត*

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងក្នុងកិច្ចប្រជុំកំពូលពិភពលោកឆ្នាំ ២០២២ នាថ្ងៃទី១១ ខែកុម្ភៈ នេះក្នុងនាមជាសហប្រធាននៃកិច្ចប្រជុំកំពូលពិភពលោក ស្តីពីសន្តិភាពនៅឧបទ្វីបកូរ៉េថា ប្រទេសកម្ពុជា និងតំបន់មេគង្គអាចផ្តល់មេរៀនស្តីពីការបង្កើតសន្តិភាព ការកសាងសន្តិភាព និងការបង្រួបបង្រួមជាតិ។

សម្តេចបានថ្លែងថា ៖ «គោលនយោបាយឈ្នះ-ឈ្នះ នៅកម្ពុជា អាចជាការជំរុញទឹកចិត្ត និងប្រភពនៃការស្រាវជ្រាវសម្រាប់ប្រទេសនានា។ យើងមិនអាចប្រើសង្គ្រាមដើម្បីបញ្ចប់សង្គ្រាមនោះទេ តែយើងត្រូវការកិច្ចសន្ទនាដោយសន្តិវិធី និងការចរចាឈ្នះ-ឈ្នះ ដើម្បីបញ្ចប់សង្គ្រាម»។




ឆ្នាំនេះជាខួបលើកទី ៧២ ឆ្នាំ នៃសង្គ្រាមកូរ៉េ ដែលបានចាប់ផ្តើមនៅថ្ងៃទី២៥ខែមិថុនាឆ្នាំ១៩៥០ ។ សង្គ្រាមបានបញ្ចប់ដោយកិច្ចព្រមព្រៀងឈប់បាញ់ នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៥៣ តែមិនមែនបញ្ចប់ដោយសន្ធិសញ្ញាសន្តិភាពអចិន្ត្រៃយ៍នោះទេ។ ទោះបីជាកិច្ចខិតខំប្រឹងប្រែងសន្តិភាពត្រូវ បានធ្វើឡើងក្នុងរយៈពេលជាច្រើនទសវត្សរ៍ក៏ដោយ ប៉ុន្តែជាអកុសល, សន្ធិសញ្ញាសន្តិភាពមិនទាន់អាចសម្រេចបាននៅឡើយ។

សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា ៖ «ហេតុដូច្នេះហើយ នេះជាពេលវេលាដ៏សំខាន់ ដើម្បីសម្រេចនូវសន្ធិសញ្ញាសន្តិភាពនៅឧបទ្វីបកូរ៉េ។ យើងត្រូវការចាំបាច់នូវសេចក្តីថ្លែងការណ៍បញ្ចប់សង្គ្រាមនៅឧបទ្វីបកូរ៉េ»។

កិច្ចប្រជុំកំពូលពិភពលោកឆ្នាំ ២០២២ បានប្រមូលផ្តុំថ្នាក់ដឹកនាំ និងអ្នកជំនាញសំខាន់ៗមកពីគ្រប់វិស័យជាង ១០០ ប្រទេស ដើម្បីចែករំលែកទស្សនៈ, ប្រាជ្ញា និងចក្ខុវិស័យរបស់ពួកគេ ស្តីពីសន្តិភាព និងវិបុលភាពនៅលើឧបទ្វីបកូរ៉េ និងតំបន់អាស៊ីប៉ាស៊ីហ្វិក។

កិច្ចប្រជុំកំពូលពិភពលោកឆ្នាំ ២០២២ បានរៀបចំឡើងនៅក្នុងអំឡុងពេលនៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយកាន់តែតឹងតែង និងវិបត្តិជាបន្តបន្ទាប់ ដែលបង្កឡើងដោយជំងឺរាតត្បាត, គម្លាតសង្គមកាន់តែរីកធំ ក៏ដូចជាគ្រោះធម្មជាតិផងដែរ។

សម្តេចតេជោ បានលើកឡើងថា ៖ «ទន្ទឹមនេះដែរ, ពិភពលោករបស់យើង គឺកំពុងតភ្ជាប់គ្នាទៅវិញទៅមក និងពឹងផ្អែកគ្នាទៅវិញទៅមកកាន់តែខ្លាំង ដូច្នេះហើយ យើងត្រូវការធ្វើការជាមួយគ្នាដើម្បី សម្របសម្រួលការឆ្លើយតបជាសកលចំពោះបញ្ហាសកលដែលកំពុងកើតឡើងនេះ ។ សន្តិភាព និងស្ថិរភាព នៅឧបទ្វីបកូរ៉េ គឺជាបញ្ហាចោទមួយផងដែរ នៅក្នុងបញ្ហាពិភពលោកដ៏តានតឹង និងស្មុគស្មាញ ដែលត្រូវការដំណោះស្រាយ»។

ឆ្លៀតក្នុងឱកាសនោះដែរ សម្តេចតេជោ បានស្នើឱ្យកូរ៉េទាំងពីរ និងភាគីពាក់ព័ន្ធនានា សម្រេចសន្ធិសញ្ញា សន្តិភាពឱ្យបានឆាប់រហ័ស ដើម្បីធានាបាននូវសន្តិភាពអចិន្ត្រៃយ៍នៅលើឧបទ្វីបកូរ៉េ។

សម្តេថា ៖ «ខ្ញុំក៏សូមអំពាវនាវ ដល់ភាគីពាក់ព័ន្ធទាំងអស់បន្តជំរុញកិច្ចសហប្រតិបត្តិការផ្អែកលើទំនុកចិត្ត និងភាពជាដៃគូយកប្រជាជន ជាស្នូលដើម្បីកសាងដំណើរឆ្ពោះទៅរកការបង្រួបបង្រួមកូរ៉េទាំងពីរដោយសន្តិភាព»៕

# កម្ពុជានឹងលុបបំបាត់គ្រោះគំរាមកំហែង ដោយសារគ្រាប់មីនប្រឆាំងមនុស្ស នៅត្រឹមឆ្នាំ ២០២៥

*អត្ថបទ៖ អមរិន្ទ ដានុត*

អត្ថបទ៖ អមរិន្ទ ដានុត

អគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC)លោក ហេង រតនា បានឱ្យដឹងថា កម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់ការលុបបំបាត់គ្រោះគំរាមកំហែង ដោយសារគ្រាប់មីនប្រឆាំងមនុស្ស នៅត្រឹមឆ្នាំ ២០២៥ ដោយចាប់ផ្តើមពីខេត្តកែប ខេត្តកណ្តាល និងរាជធានីភ្នំពេញ។

លោកបានលើកឡើងថាអង្គភាពស៊ីម៉ាក់បានបញ្ចប់កិច្ចប្រតិបត្តិការរំដោះផ្ទៃដីរងផលប៉ះពាល់ដោយគ្រាប់មីនប្រឆាំងមនុស្ស ដែលបានដឹងនិងមានកំណត់ត្រាពហុកោណក្នុងទិន្នន័យថ្នាក់ជាតិ (Landmines known areas with polygon records in National Database) ស្ថិតក្នុងខេត្តកែប ខេត្តកណ្តាល និងរាជធានីភ្នំពេញ។

លទ្ធផលដែលបានសម្រេចជាស្ថាពរក្នុងនោះមាន ខេត្តកែប មានចំនួន ៨ ពហុកោណ (ចម្ការមីន) ស្មើនឹងផ្ទៃដី ៦៩,៨ ហិចតា, ខេត្តកណ្តាល មានចំនួន ៣ ពហុកោណ ស្មើនឹងផ្ទៃដី ៦៤ ហិចតា និងរាជធានីភ្នំពេញ មានចំនួន ៨ ពហុកោណ ស្មើនឹងផ្ទៃដី ៩៨៣ ហិចតា។

សម្រាប់ទិសដៅបន្ត លោក ហេង រតនា បានបញ្ជាក់ថា ៖ «អង្គភាពស៊ីម៉ាក់បានចល័តកម្លាំងចូលទៅខេត្តព្រះសីហនុខេត្តកំពតខេត្តកំពង់ចាម និងខេត្តតាកែវ ដែលជាគោលដៅអាទិភាពក្នុងការ បញ្ចប់ បញ្ហាគ្រាប់មីនប្រឆាំង មនុស្ស ក្នុងឆ្នាំ២០២២ នេះ»។

សូមបញ្ជាក់ថាការប្រកាសថាខេត្តគ្មានតំបន់គំរាមកំហែងដោយសារគ្រាប់មីនប្រឆាំង មនុស្ស ឬហៅថា «ខេត្តគ្មានគ្រាប់មីនប្រឆាំងមនុស្ស» វាមិនមានន័យថាខេត្តទាំងនោះ អស់បញ្ហាជាមួយសំណល់យុទ្ធភណ្ឌ សង្គ្រាមនោះទេ។ ការពិតអាច បន្តមាន បញ្ហាសំណល់យុទ្ធភណ្ឌមិនទាន់ផ្ទុះពីសង្គ្រាមដទៃទៀត ដូចជាគ្រាប់បែកចង្កោម គ្រាប់បែកទម្លាក់ពីយន្តហោះ និងសំណល់គ្រាប់មិនទាន់ផ្ទុះផ្សេងក្រៅពីគ្រាប់មីនប្រឆាំងមនុស្ស។

បញ្ហាគ្រាប់មីនប្រឆាំងមនុស្សស្ថិតនៅក្រោមអនុសញ្ញាអន្តរជាតិអូតាវ៉ា ដែលមាន ១៦៤ ប្រទេស គឺជាសមាជិកហត្ថលេខី។ ក្នុងចំនួននេះមានប្រទេស ១៣៣ ជារដ្ឋសមាជិក ដោយបូករួមទាំង កម្ពុជាផងដែរ។

រាជរដ្ឋាភិបាលកម្ពុជាក្នុងនាមជារដ្ឋសមាជិកមួយយ៉ាងសកម្ម បានប្តេជ្ញាអនុវត្តអនុសញ្ញានេះយ៉ាងពេញលេញ ដោយអនុម័តផែនការយុទ្ធសាស្រ្ត «កម្ពុជាគ្មានគ្រាប់មីនប្រឆាំងមនុស្សត្រឹមឆ្នាំ២០២៥»។

លោក ហេង រតនា បានលើកឡើងទៀតថា ៖ «ដូចដែលបានដឹងរួចមកហើយថា កម្ពុជាទទួលរងគ្រោះដោយសារសង្គ្រាមរយៈពេលយូរឆ្នាំ នាំឱ្យផលវិបាកនៃសំណល់យុទ្ធភណ្ឌសង្គ្រាម មាន



សភាពធ្ងន់ធ្ងរជាងគេលើពិភពលោក។ ហេតុនេះការដោះស្រាយបញ្ហាសំណល់យុទ្ធភណ្ឌសង្គ្រាមគ្រប់ប្រភេទ ឱ្យអស់ត្រឹមឆ្នាំ២០២៥ មិនមែនជាកិច្ចការងាយស្រួលនោះទេ»។

ផ្អែកតាមផែនការរបស់រាជរដ្ឋាភិបាល អង្គភាពស៊ីម៉ាក់បានដាក់ចេញនូវផែនការយុទ្ធសាស្រ្តរយៈពេល ៤ឆ្នាំ (២០២២-២០២៥) ដើម្បីរំដោះផ្ទៃដីរងផលប៉ះពាល់ដោយសារគ្រាប់មីនប្រឆាំងមនុស្ស ដែលបានដឹងនិងមានកំណត់ត្រាក្នុងទិន្នន័យថ្នាក់ជាតិចំនួនជាង ៧០០ គីឡូម៉ែត្រក្រឡា គឺប្រមាណ ៩០% នៃបញ្ហាគ្រាប់មីនដែលកំពុងនៅសេសសល់៕

# កម្ពុជាគ្រោងលុបបំបាត់ជំងឺគ្រុនចាញ់ ប្រភេទផ្លាស់ស្មូដ្យូម ហ្វាល់ស៊ីប៉ារ៉ូម នៅឆ្នាំ២០២៣ ខណៈ៤ឆ្នាំនេះមិនមានអត្រាស្លាប់ឡើយ

*អត្ថបទ៖ អមរិន្ទ ដានុត*

ក្រសួងសុខាភិបាលនៃប្រទេសកម្ពុជា គ្រោងលុបបំបាត់ជំងឺគ្រុនចាញ់ ប្រភេទផ្លាស់ស្មូដ្យូមហ្វាល់ស៊ីប៉ារ៉ូម (P.Falciparum) នៅឆ្នាំ២០២៣ ខណៈដែលក្នុងរយៈពេល៤ឆ្នាំចុងក្រោយនេះគឺ ចាប់ពីឆ្នាំ ២០១៨ ដល់ ២០២១ កម្ពុជាពុំមានករណីស្លាប់ដោយជំងឺគ្រុនចាញ់ឡើយ ហើយករណីឈឺក៏មានការធ្លាក់ចុះជាបន្តបន្ទាប់ផងដែរ។





នេះជាការលើកឡើងរបស់លោក ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល ក្នុងសន្និបាតបូកសរុបការងារឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ កាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ ក្រោមប្រធានបទ «ជំហានចុងក្រោយឆ្ពោះទៅលុបបំបាត់ជំងឺគ្រុនចាញ់ ប្រភេទផ្លាស់ស្មូដ្យូម ហ្វាល់ស៊ីប៉ារ៉ូម ឆ្នាំ២០២៣»។

លោកបានថ្លែងនាឱកាសនោះថា ការរកឃើញជំងឺគ្រុនចាញ់ គឺត្រូវព្យាបាលប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាព ព្រមជាមួយនឹងការតាមដានគ្រប់ករណីជំងឺគ្រុនចាញ់ទាំងអស់ រួមទាំងផ្តល់នូវមធ្យោបាយការពារផ្ទាល់ខ្លួន ប្រកបដោយប្រសិទ្ធភាព ឲ្យបានយ៉ាងហោចណាស់ ៩០ភាគរយ ក្នុងចំណោមប្រជាជនដែលមានហានិភ័យខ្ពស់។



លោក ម៉ម ប៊ុនហេង មានប្រសាសន៍ថា៖ «បន្ថែមពីនេះ ក៏ត្រូវពង្រឹងការអង្កេតតាមដានជំងឺគ្រុនចាញ់ របស់កម្មវិធីជាតិ និងប្រព័ន្ធតាមដាន និងវាយតម្លៃ ដែលសមស្រប សម្រាប់សកម្មភាពលុបបំបាត់ និងកំចាត់ជំងឺគ្រុនចាញ់ រួមទាំងការទប់ស្កាត់ការកើតមានឡើងវិញនៃជំងឺគ្រុនចាញ់ផងដែរ»។

លោករដ្ឋមន្ត្រីក៏បានអំពាវនាវឱ្យភាគីពាក់ព័ន្ធទាំងអស់ត្រូវយកចិត្តទុកដាក់ទៀត ពិសេសការលើកកម្ពស់សមត្ថភាពមន្ត្រីសុខាភិបាល ដើម្បីគ្រប់គ្រងពង្រឹងសកម្មភាព ធានាឲ្យបាននិរន្តរភាពនៃកិច្ចខិតខំប្រឹងប្រែងក្នុងការកំចាត់ និងលុបបំបាត់ជំងឺគ្រុនចាញ់ ជាពិសេសនៅថ្នាក់ខេត្ត និងថ្នាក់ស្រុកប្រតិបត្តិ។

លោកបានសង្កត់ធ្ងន់ថា ៖ «ដើម្បីសម្រេចបានតាមគម្រោងការនេះ យើងត្រូវពង្រឹងពីការគ្របដណ្តប់ផ្តល់មុងជ្រលក់ជូនដល់ប្រជាជនចល័ត និងជនចំណាកស្រុកឱ្យបាន១០០ភាគរយ ជាពិសេសអ្នកស្ម័គ្រចិត្តព្យាបាលជំងឺគ្រុនចាញ់ចល័ត ដោយជួយណែនាំឱ្យប្រជាពលរដ្ឋដែលចល័តចូលព្រៃ ត្រូវតែប្រើប្រាស់មុងឱ្យបានគ្រប់ៗគ្នា និងត្រូវពង្រឹងវិសាលភាពព្យាបាលជំងឺរីវ៉ាក់ ដោយប្រើថ្នាំព្រីម៉ាគីន»។

ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ លោកវេជ្ជបណ្ឌិត ហ៊ុយ រ៉េកុល ក៏បានលើកឡើងថា ផ្អែកតាមលទ្ធផលការងារ និងសមិទ្ធផលរបស់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម និងកម្មវិធីជាតិប្រយុទ្ធនឹងជំងឺដង្កូវព្រូន បាននឹងកំពុងទទួលបានដំណើរការអភិវឌ្ឍន៍ជោគជ័យជាបន្តបន្ទាប់។

លោក ហ៊ុយ រ៉េកុល បានថ្លែងថា ៖ «ការចូលរួមចំណែកទទួលខុសត្រូវទាំងនេះ នឹងនៅតែកើតមានជាបន្តបន្ទាប់សម្រាប់រាល់ការងារវិនិយោគប្រតិបត្តិការលើកម្មវិធីជាតិទាំងបី ក្នុងទិសដៅកាត់បន្ថយអត្រាឆ្លង អត្រាឈឺ និងអត្រាស្លាប់ដោយជំងឺគ្រុនចាញ់ គ្រុនឈាម និងដង្កូវព្រូន ពិសេសឈានឆ្ពោះទៅគ្មានជំងឺគ្រុនចាញ់ និងជំងឺស៊ីស្ដូ នាឆ្នាំ២០២៥ ដែលជាជ្រុងមួយនៃការចូលរួមចំនែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន»។

យោងតាមរបាយការណ៍របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ បានឱ្យដឹងថា ក្នុងឆ្នាំ២០២១ ករណីជំងឺគ្រុនចាញ់មានចំនួន ៤.២៧៩ករណី ក្នុងនោះថយចុះចំនួន ៥៤ភាគរយ បើប្រៀបធៀបឆ្នាំ២០២០ ខណៈករណីស្លាប់ដោយសារជំងឺគ្រុនចាញ់គឺសូន្យតាំងពីឆ្នាំ២០១៨មក បានន័យថា សម្រេចបានជោគជ័យនូវសូចនាករអត្រាស្លាប់ ៣ឆ្នាំមុនគោលដៅឆ្នាំ២០២០ ។

របាយការណ៍ដដែលបានបន្តថា សម្រាប់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម គឺ នៅឆ្នាំ២០២១ អត្រាជំងឺគ្រុនឈាមមានចំនួនសរុប ១.៩០៣ករណី ក្នុងនោះឈឺស្លាប់ ចំនួន៨នាក់ ស្មើនឹង ០,១ភាគរយ ថយចុះប្រហែល៥ដង និងអ្នកស្លាប់ថយចុះចំនួន៥០ភាគរយ បើប្រៀបធៀបនឹងឆ្នាំ២០២០ ដែលមានចំនួន ១១.៩៧៧ករណី និងស្លាប់ ១៦នាក់ ហើយករណីកើតជំងឺគ្រុនឈាមច្រើនជាងគេក្នុងឆ្នាំ២០២១ មានខេត្តកំពង់ស្ពឺ រាជធានីភ្នំពេញ និងខេត្តកណ្តាល។

ដោយឡែក សម្រាប់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺដង្កូវព្រូន អត្រាស្លាប់របស់កុមារនិងមាតាតាមរយៈយុទ្ធសាស្ត្រជាតិប្រយុទ្ធនិងគ្រប់គ្រងជំងឺដង្កូវព្រូន ក្នុងទិសដៅលើកកំពស់សុខភាពរបស់ប្រជាជនប្រឈមនឹងជំងឺដង្កូវព្រូនស៊ីស្ដូ ព្រូនជើងដំរី ព្រូនឆ្លងតាមដី និងដង្កូវព្រូនពោះវៀនដទៃទៀត ប្រកបដោយនិរន្តរភាព៕

# កម្ពុជារងគ្រោះធម្មជាតិបង្កឱ្យមានមនុស្សស្លាប់និងរងរបួសជាច្រើន ក្នុងឆ្នាំ២០២១

*អត្ថបទ៖ អមរិន្ទ ដានុត*

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានឱ្យដឹងថា ក្នុងឆ្នាំ២០២១ រាជធានី-ខេត្ត ចំនួន១៨បានរងផលប៉ះពាល់ដោយសារជំនន់ទឹកភ្លៀង ដែលបង្កឱ្យប្រជាជន ៤៩,២៣៦ គ្រួសារប៉ះពាល់ និងមនុស្សចំនួន ១៣ នាក់ស្លាប់។

របាយការណ៍ដដែលបានឱ្យដឹងទៀតថា កម្ពុជាក៏រងនូវការវាយប្រហារពីខ្យល់កន្ត្រាក់ ដែលបានប៉ះពាល់ដល់២៥រាជធានី-ខេត្ត បង្កឱ្យផ្ទះរលំ និងខូចខាតធ្ងន់ធ្ងរចំនួន ១,០២២ខ្នង និងផ្ទះរបើកដំបូលចំនួន ៧,២៤៩ខ្នង។

ចំណែកសាលារៀនវិញមានការប៉ះពាល់ដោយការរបើកដំបូលចំនួន ៤៨អគារ, ខូចខាតតូបផ្សារ ១១២តូប, អគាររដ្ឋបាលផ្សេងៗ និងវត្តអារាម របើកដំបូល ២៣កន្លែង។

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានបញ្ជាក់ថា៖ «ករណីខ្យល់កន្ត្រាក់នេះបានធ្វើឱ្យមនុស្សស្លាប់ចំនួន ៩នាក់ និងរបួស ៧៦នាក់ រីឯករណីរន្ទះបាញ់ ក៏បានសម្លាប់មនុស្ស ៨៣នាក់ និងរបួស ៥០នាក់ និងងាប់គោក្របី ៥៧ក្បាលផងដែរ»។

លោក ឡាំ ហេងហួត អនុប្រធាន និងជាអគ្គលេខាធិការគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានលើកឡើងក្នុងកិច្ចប្រជុំជាមួយដៃគូអភិវឌ្ឍន៍ក្នុងការឆ្លើយតបនឹងស្ថានភាពគ្រោះមហន្តរាយនៅកម្ពុជា ដើម្បីត្រៀមលក្ខណៈឆ្លើយតប និងពិនិត្យលើការងារអនុវត្តនាឆ្នាំ ២០២១ និងចែករំលែកនូវផែនការការងារសម្រាប់ឆ្នាំ២០២២ថា ថ្នាក់ដឹកនាំតែងតែយកចិត្តទុកដាក់គិតគូរដោះស្រាយបន្ទាន់លើគ្រប់ទិដ្ឋភាព ដោយការឆ្លើយតប សង្គ្រោះបន្ទាន់ត្រូវបានការយកចិត្តទុកដាក់ខ្ពស់ ដោយមិនទុកឱ្យប្រជាជនណាម្នាក់ស្លាប់ ដោយខ្វះការទទួលខុសត្រូវឡើយ។

លោកបានថ្លែងថា៖ «ជាចម្បង ប្រមុខរាជរដ្ឋាភិបាល តែងគិតគូរដល់ស្ត្រី កុមារ ចាស់ជរា ជនមានពិការភាព ដែលត្រូវបានចាត់ទុកជាក្រុមងាយរងគ្រោះ ហើយស្ត្រីទៀតសោធ មានខ្លះជាមេគ្រួសារត្រូវរ៉ាប់រងបន្ទុកធ្ងន់ធ្ងរទៅលើក្រុមងាយរងគ្រោះនេះទៀតផង នៅមុនពេល ក្នុងពេល និងក្រោយពេលគ្រោះមហន្តរាយ»។

នាយិកាអង្គការ Save the Children ប្រចាំនៅកម្ពុជា និងជាសហប្រធានភ្នាក់ងារសហប្រជាជាតិដៃគូអភិវឌ្ឍន៍ JAG លោកស្រី អេលីហ្សាបេតភៀស បានឱ្យដឹងថា ក្នុងរយៈពេល ២ ឆ្នាំចុងក្រោយនេះ ការត្រៀមលក្ខណៈលើបញ្ហាគ្រោះមហន្តរាយមានភាពស្មុគស្មាញ ដោយសារមានបញ្ហាជាច្រើនកើតឡើងដំណាលគ្នា ដូចជាគ្រោះទឹកជំនន់ និងលាររាតត្បាតជំងឺកូវីដ-១៩។

លោកស្រីថា ទោះបីជាមានភាពស្មុគស្មាញក៏ដោយ អង្គការក្រៅរដ្ឋាភិបាលអាចរួមគ្នាជាមួយរដ្ឋាភិបាលកម្ពុជា អង្គការសហប្រជាជាតិ និងសង្គមស៊ីវិល ដើម្បីឆ្លើយតបទាន់ពេលវេលាផងដែរ៕

# សម្តេច ហ៊ុន សែន៖ «ស្ត្រីបានចូលរួមចំណែកកសាងប្រទេស ក្នុងកិច្ចការងារជាច្រើនវិស័យ»



*អត្ថបទ៖ អមរិន្ទ ដានុត*

ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានលើកឡើងថា ស្ត្រីបានរួមចំណែកយ៉ាងសកម្មនៅក្នុងការកសាង និងអភិវឌ្ឍសង្គមជាតិ ហើយបច្ចុប្បន្ននេះ ស្ត្រីបានចូលរួមចំណែកក្នុងកិច្ចការងារជាច្រើនវិស័យផងដែរ។

សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន និងជាអនុប្រធានកិត្តិយស នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី បានថ្លែងឡើងដូចនេះ ក្នុងពេលអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២២ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី នាថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២កន្លងទៅនេះ។

សម្តេចក៏បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដែលបានរួមចំណែកយ៉ាងសកម្មក្នុងការកសាង និងអភិវឌ្ឍសង្គមជាតិ។

សម្តេចតេជោ ហ៊ុន សែន មានប្រសាសន៍ថា ៖ «បច្ចុប្បន្ន ស្ត្រីបានចូលរួមចំណែកក្នុងកិច្ចការងារជាច្រើនវិស័យ»។

នាក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២២ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីនោះដែរ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាតំណាងលោកស្រីអ៊ឹុងកន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក៏បានលើកឡើងដែរថា ការអភិវឌ្ឍសមត្ថភាពស្ត្រីជាថ្នាក់ដឹកនាំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការអភិវឌ្ឍសមត្ថភាពដល់ស្ត្រីជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការជានារី នៅថ្នាក់ជាតិ ត្រូវបានយកចិត្តទុកដាក់ខ្ពស់ដោយថ្នាក់ដឹកនាំស្ថាប័ន។



ពីឆ្នាំ២០២០-២០២១ ស្ត្រីចំនួន២២៣៥ នាក់ នៃចំនួនអ្នកចូលរួមសរុប៣៨៧១នាក់ បានចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងជំនាញនានាទាំងក្នុងប្រទេស និងក្រៅប្រទេស។

លោកស្រីបានបន្តថា នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងកិច្ចការនារី បានរៀបចំកម្មវិធីអភិវឌ្ឍន៍សមត្ថភាពមន្ត្រីកិច្ចការនារីក្នុងការអនុវត្តការងារការស្វែងរកការគាំទ្រមតិ ការបញ្ជ្រាបយេនឌ័រ និងបរិយាបន្ន សីលធម៌សង្គម និងភាពជាអ្នកដឹកនាំ និងដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគ ឃុំ សង្កាត់ និងសមាហរណកម្មផែនការឃុំ សង្កាត់ ថ្នាក់ ក្រុង ស្រុក ខណ្ឌ។

ក្រសួងកិច្ចការនារី ក៏បានបើកវគ្គតាមប្រព័ន្ធអនឡាញ ដើម្បីពង្រឹងតួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងភារកិច្ចរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ អ្នកចូលរួម ១,១២៣ នាក់(ស្ត្រី៨៤០នាក់)។

លោកស្រី ជូ ប៊ុនអេង បានថ្លែងថា ៖ «ដូចរៀងរាល់ឆ្នាំកន្លងមក ឆ្នាំ២០២២ នេះ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី បានសម្របសម្រួលរៀបចំរបាយការណ៍វឌ្ឍនភាពឆ្នាំ២០២០-២០២១ និងផែនការសកម្មភាពការងារឆ្នាំ២០២២ ដោយមានការចូលរួមផ្តល់ធាតុចូលរបាយការណ៍ពីក្រសួងស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ និងការផ្តល់យោបល់ពីក្រុមការងារបច្ចេកទេសយេនឌ័រ ព្រមទាំងការឯកភាពពីសមាជិក សមាជិកានៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី»។

របាយការណ៍លទ្ធផលការងារឆ្នាំ២០២០-២០២១ បង្ហាញពីវឌ្ឍនភាពការប្រឈមថ្មីៗ និងចំណុចសេសសល់ទាំងឡាយ ដែលទាំងអស់គ្នាចាំបាច់ត្រូវខិតខំបន្តការដោះស្រាយក្នុងបរិការណ៍នៃជំងឺកូវីដ-១៩ ដើម្បីស្តារ និងជំរុញការអភិវឌ្ឍគ្រប់វិស័យ តាមរយៈការបន្តអនុវត្តវិធានការផ្នែកគោលនយោបាយ កម្មវិធីនិងសកម្មភាពជាក់លាក់នានា ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ដើម្បីការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន និងចីរភាព។

គួរបញ្ជាក់ថា «ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី» មានព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ជាព្រះប្រធានកិត្តិយស និងមានសម្តេចតេជោ ហ៊ុន សែន ជាអនុប្រធានកិត្តិយស។ ចាប់តាំងពីឆ្នាំ២០០៦មក ថ្នាក់ដឹកនាំនៃក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី តែងតែបើកកិច្ចប្រជុំជាទៀងទាត់រៀងរាល់មួយឆ្នាំម្តង។

កិច្ចប្រជុំនេះ ធ្វើឡើងដើម្បីតាមដាន និងត្រួតពិនិត្យរាល់សកម្មភាពការងារ និងការអនុវត្តរាល់អនុសាសន៍លើការងារមួយចំនួនរបស់ ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី ក្នុងការចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ដើម្បីលើកកម្ពស់សិទ្ធិសេរីភាពឋានៈតួនាទី ពិសេសការចូលរួមដោះស្រាយរាល់ការងារជាអាទិភាពនានារបស់ស្ត្រី៕

# លោកស្រី អេនចូលីណា ជូលី ដាក់សម្ពោធជាផ្លូវការនៃកម្មវិធីចិញ្ចឹមឃ្មុំសម្រាប់ស្ត្រី (Women for Bees) នៅកម្ពុជា

អត្ថបទ៖ អមរិន្ទ ដានុត

តារាភាពយន្តហូលីវ៉ូដ លោកស្រី អេនចូលីណា ជូលី (Angelina Jolie) បានមកបំពេញបេសកកម្មក្នុងរមណីយដ្ឋានអង្គរដើម្បីបង្កើតកម្មវិធីចិញ្ចឹមឃ្មុំសម្រាប់ស្ត្រី។

លោកស្រី Angelina Jolie បានមកបំពេញបេសកកម្មការងារនៅឧទ្យានជាតិអង្គរកាលពីថ្ងៃទី២០ខែកុម្ភៈ ឆ្នាំ២០២២ កន្លងទៅនេះដោយបានចូលរួមពិធីសម្ពោធជាផ្លូវការនៃកម្មវិធីចិញ្ចឹមឃ្មុំសម្រាប់ស្ត្រី(Women for Bees) ក្រោមកិច្ចសហការជាមួយអង្គការយូណេស្កូ និងសម្របសម្រួលដោយអាជ្ញាធរជាតិអប្សរា។

កម្មវិធីចិញ្ចឹមឃ្មុំនេះមានគោលបំណងជួយអភិរក្សប្រភេទឃ្មុំ Apis cerana និង Apis dorsata ដែលមានដើមកំណើតនៅក្នុងឧទ្យានអង្គរ លើកកម្ពស់ការចិញ្ចឹមឃ្មុំប្រកបដោយចីរភាព និងពង្រឹងសមត្ថភាពស្ត្រីក្នុងការរកប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់ក្នុងគ្រួសារ និងសហគមន៍របស់ពួកគេ។

«ស្ត្រីដើម្បីឃ្មុំ» ជាសកម្មភាពដើម្បីសង្គមមួយដែលផ្តួចផ្តើមដោយ Guerlain និង UNESCO។ គម្រោងស្ត្រីដើម្បីឃ្មុំ នឹងអប់រំបណ្តុះបណ្តាលស្ត្រីចំនួន៥០នាក់ដែលមកពីប្រទេសផ្សេងៗគ្នា ដើម្បីឲ្យក្លាយជាអ្នកជំនាញចិញ្ចឹមឃ្មុំ និងដើម្បីជួយបង្កើតការងារដល់ស្ត្រីផងដែរ ហើយពួកគាត់នឹងជួយក្នុងការបង្កើនការបន្តពូជឃ្មុំទូទាំងពិភពលោក។

សូមបញ្ជាក់ថា លោកស្រី Angelina Jolie គឺជាស្ថាបនិកនៃគម្រោង UNESCO-GUERLAIN «Women for bees» ដែលឧបត្ថម្ភដោយក្រុមហ៊ុន GUERLAIN។ Guerlain បានជ្រើសតាំងលោកស្រី អេនចូលីណា ជូលី ជា «ម្តាយធម៌» របស់កម្មវិធីស្ត្រីដើម្បីឃ្មុំនេះ។ ក្នុងតួនាទីនេះ អ្នកស្រីជូលី និងត្រូវធ្វើដំណើរទៅជួប ស្ត្រីដែលជាសិក្ខាកាមក្នុងកម្មវិធីនេះដោយផ្ទាល់ ដើម្បីត្រួតពិនិត្យដំណើរការរបស់ពួកគេ។

លោកស្រី អេនចូលីណា ជូលី ធ្លាប់បានលើកឡើងក្នុងទស្សនាវដ្តី People ថា នៅពេលដែលស្ត្រីមានជំនាញ និងចំណេះដឹងសភាវគតិរបស់ពួកគេគឺជួយលើកស្ទួយនៅផ្សេងទៀត។

លោកស្រីថា ៖ «ខ្ញុំពិតជាមានការ រំភើបនឹងការជួបក្រុមស្ត្រីពីជុំវិញពិភពលោកដែលចូលរួមក្នុងកម្មវិធីនេះ។ ខ្ញុំទន្ទឹងរង់ចាំដើម្បីជួប និងរៀនសូត្រពីវប្បធម៌ និងបរិស្ថានរបស់ពួកគេ ព្រមទាំងស្វែងយល់តួនាទីរបស់ឃ្មុំនៅក្នុងនោះ»។

លោកស្រីសង្ឃឹមថាវគ្គបណ្តុះបណ្តាលនេះនឹងអាចពង្រឹងភាពជាឯករាជ្យ និងជីវភាពរបស់គាត់ ក៏ដូចជាសហគមន៍ដែលគាត់រស់នៅ។

ក្នុងបេសកកម្មលើកនេះដែរ លោកស្រីអេនចូលីណា ជូលី ក៏បានទៅទស្សនាប្រាសាទអង្គរវត្តផងដែរ។

អាជ្ញាធរជាតិអប្សរា បានលើកឡើងថាការបង្ហាញវត្តមានដ៏សំខាន់ក្នុងបេសកកម្មរបស់ខ្លួននៅពេលនេះ តារាហូលីវ៉ូដរូបនេះក៏បានជួយផ្សព្វផ្សាយតំបន់រមណីយដ្ឋានអង្គរ ទៅកាន់ពិភពលោកថែមមួយកម្រិតទៀត។ ជាពិសេសក្នុងអំឡុងពេលវិបត្តិជំងឺកូវីដ-១៩ដើម្បីបញ្ជាក់ថា កម្ពុជាជាគោលដៅទេសចរណ៍ប្រកបដោយសុវត្ថិភាព៕



# ការនាំចេញផលិតផលកសិកម្ម២ខែដើមឆ្នាំទទួលបានកំណើន៩,៥១ ភាគរយ





*អត្ថបទ៖ អរិយបុត្រ*

នារយៈពេល២ខែដើមឆ្នាំ២០២២កន្លងទៅនេះ ការនាំចេញកសិផលទៅក្រៅប្រទេសដែលអគ្គនាយកដ្ឋានកសិកម្មទទួលបានផ្អែកលើប្រព័ន្ធទិន្នន័យគ្រឹះភូតគាមអនាម័យជាតិ (National Phytosanitary Database)ទទួលបានកំណើនរហូតដល់ទៅ ៩,៥១ភាគរយ។

លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឲ្យដឹងថា កសិផលមានបរិមាណសរុប ១.៨៣៥.៤៧៥ តោន ត្រូវបាននាំចេញទៅកាន់ទិសដៅ ៥២ ប្រទេស គឺមានការកើនឡើងចំនួន ១៥៩.៣៣១តោន ស្មើនឹង ៩,៥១% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១ ដែលទទួលបានត្រឹមតែ ១.៦៧៦.១៤៤តោន។

លោកបានបន្តថា កសិផលសំខាន់ៗដែលបាននាំចេញមានដូចជា អង្ករ ស្រូវ និង ផលិតផលផ្សេងៗទៀត ។

លោកបានបន្តថា ការនាំចេញអង្ករមានបរិមាណ ចំនួន ១០៣.០៥៨ តោន កើនឡើងចំនួន ២៦.៨៣៦តោន ឬស្មើនឹង ៣៥,២១% បើធៀបនឹងបរិមាណនាំចេញក្នុងរយៈពេល២ខែដើមឆ្នាំ២០២១ ដែលមានចំនួន ៧៦.២២២តោន។ ប្រភពដដែលបានបន្តថា បរិមាណអង្ករបាននាំចេញទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន ២០ប្រទេស មានបរិមាណសរុបចំនួន ២៦.៥០៧តោន កើនឡើងចំនួន ៧.៥១១តោន ស្មើនឹង ៣៩,៥៤% ។ ទិសដៅប្រទេសចិនមានបរិមាណសរុបចំនួន ៥៦.៣៨៥តោន កើនឡើងចំនួន ១៨.៧៥៥តោន ស្មើនឹង ៤៩,៨៤%។ ទិសដៅអាស៊ានចំនួន ៣ប្រទេស មានបរិមាណសរុបចំនួន ៩.៣៧០តោន កើនឡើងចំនួន ៣.១៤១តោន ស្មើនឹង ៥០,៤៣% និងទិសដៅដទៃទៀតចំនួន១៦ប្រទេស មានបរិមាណសរុប ១០.៧៩៦តោន ថយចុះចំនួន ២.៥៧១តោន ឬ ធ្លាក់ចុះ១៩,២៣%។

លោកបានបន្តថា ក្រុមហ៊ុនដែលបាននាំចេញអង្ករមានចំនួន ៤១ក្រុមហ៊ុន ហើយបរិមាណអង្ករដែលបាននាំចេញដោយក្រុមហ៊ុនធំៗចំនួន១០ មានរហូតដល់ ៧៧.០៣៩តោន (៧៥,០២%) និងក្រុមហ៊ុន៣១ដទៃទៀតបាននាំចេញត្រឹមតែ ២៦.០១៩តោន (២៤,៩៨%)។

លោកបានបន្ថែមថា ការនាំចេញស្រូវវិញមានបរិមាណ ចំនួន ៦៥១.១០១ តោន ទៅកាន់ប្រទេសវៀតណាម ដោយមានវិញ្ញាបនបត្រភូតគាមអនាម័យចំនួន ៤១៣.៧៧៥តោន កើនឡើងចំនួន ៩២.០៦៨ តោន ឬ១៦,៤៧% បើធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០២១ ដែលមានចំនួន ៥៥៩.០៣៣តោន ដោយឡែក ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករមាន បរិមាណនាំចេញចំនួន ១.៣១៨.៦៤២ តោន កើនឡើងចំនួន ៦.៥៧០ តោន ស្មើនឹង ០,៥០% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១ ដែលមានចំនួន ១.៣១២.០៧២តោន៕

# រាជរដ្ឋាភិបាលប្រកាសផ្តល់មូលនិធិបន្ថែម១០០លានដុល្លារសម្រាប់សហគ្រាសធុនតូចនិងមធ្យម





*អត្ថបទ៖ អរិយបុត្រ*

រាជរដ្ឋាភិបាលតាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានប្រកាសកាលពីពេលថ្មីៗនេះ ពីការបន្ថែមមូលនិធិចំនួន ១០០ លានដុល្លារ សម្រាប់ធនាគារសហគ្រាសធុនតូចនិងមធ្យម ព្រមទាំងធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម ។

កញ្ចប់ជំនួយសម្រាប់គាំទ្រដល់សហគ្រាសធុនតូចនិងមធ្យមនេះ ត្រូវបានប្រកាសដោយ លោក អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅខែ កុម្ភៈកន្លងទៅថ្មីៗនេះ ។

លោក អូន ព័ន្ធមុនីរ័ត្ន បានឲ្យដឹងថា មូលនិធិចំនួន ១០០ លានដុល្លារនេះត្រូវបានដាក់បន្ថែមលើគម្រោងមូលនិធិហិរញ្ញប្បទាន ដែលមានស្រាប់សម្រាប់ធនាគារនិងស្ថាប័នហិរញ្ញវត្ថុខាងលើ ដើម្បីគាំទ្រដល់សហគ្រាសធុនតូច និង មធ្យម ព្រមទាំងវិស័យកសិកម្ម ដែលជាវិស័យ សំខាន់នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចជាតិ ទាំងនៅក្នុងការបង្កើតការងារ ការកែលម្អជីវភាពរស់នៅរបស់ប្រជាជន និង កំណើនសេដ្ឋកិច្ចជាតិ ។

គួររំលឹកថា មូលនិធិបន្ថែមនេះ នឹងត្រូវផ្តល់ជូនធនាគារសហគ្រាសធុនតូចនិងមធ្យមចំនួន ៥០លានដុល្លារ សម្រាប់បន្តគម្រោងសហហិរញ្ញប្បទានទ្រទ្រង់ សហគ្រាសធុនតូចនិងមធ្យម ដំណាក់កាលទី២ដែលធ្វើឲ្យបដិភាគរបស់រាជរដ្ឋាភិបាលមានចំនួនរហូតដល់ទៅ ១២០ លានដុល្លារហើយមូលនិធិ ៥០ លានដុល្លារទៀត នឹងត្រូវផ្តល់ជូនទៅ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម សម្រាប់កម្មវិធីហិរញ្ញប្បទានពិសេស ដែលនៅក្នុងនោះ ថវិកា ១០ លានដុល្លារ នឹងប្រើប្រាស់ក្នុងវិស័យស្រូវនិងអង្ករ និង ៤០ លានដុល្លារទៀត នឹងប្រើប្រាស់សម្រាប់ការផ្តល់ហិរញ្ញប្បទានផ្ទាល់ក្នុងទំហំ ៥០ ភាគរយនិងសម្រាប់កម្មវិធីសហហិរញ្ញប្បទានចែករំលែកហានិភ័យជាមួយនឹងគ្រឹះស្ថានហិរញ្ញវត្ថុ ក្នុងទំហំ៥០ ភាគរយ សំដៅគាំទ្រដល់អនុវិស័យ ផ្លែឈើ ការចិញ្ចឹមសត្វ វារីវប្បកម្មនិង ការកែច្នៃផលិតផលកសិកម្មជាដើម៕





# ក្រសួងបរិស្ថាននិងអង្គការដៃគូបេ្តជ្ញាធ្វើឱ្យប្រសើរឡើងនូវការអភិរក្សជីវៈចម្រុះក្នុងតំបន់ការពារទេសភាពបឹងព្រែកល្ពៅ

*អត្ថបទ៖ អមរិន្ទ ដានុត*

ក្រសួងបរិស្ថាន អង្គការជីវិតធម្មជាតិនៅកម្ពុជា អង្គការជីវិតសត្វស្លាបអន្តរជាតិ និងអង្គការ The Wildfowl & Wetlands Trust បាននឹងកំពុងអនុវត្តគម្រោងក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការអភិរក្សជីវៈចម្រុះ និងលើកកម្ពស់ជីវភាពសហគមន៍នៅក្នុងតំបន់ការពារទេសភាពបឹងព្រែកល្ពៅ។

តំបន់ការពារទេសភាពបឹងព្រែកល្ពៅ គឺជាតំបន់ដីសើមដ៏មានសក្តានុពលមួយនៅក្នុងប្រទេសកម្ពុជា ដែលមានទីតាំងភូមិសាស្រ្តស្ថិតនៅក្នុងស្រុកបុរីជលសារ និងស្រុកកោះអណ្តែត ខេត្តតាកែវ។ តំបន់មានផ្ទៃដីទំហំ ៨៣០៥ហិកតា និងសម្បូរទៅដោយជីវៈចម្រុះជាច្រើនប្រភេទក្នុងមានសត្វស្លាបចំនួន១៣២ប្រភេទ មច្ឆជាតិចំនួន១៣៨ប្រភេទ និងរុក្ខជាតិទឹក៣០ប្រភេទ។

ក្នុងដំណើរទស្សនកិច្ចរបស់ប្រតិភូក្រសួងបរិស្ថានក្នុងការស្វែងយល់អំពីវឌ្ឍនភាពគម្រោងអភិរក្សតំបន់ដីសើម នៅតំបន់ការពារទេសភាពបឹងព្រែកល្ពៅនេះ លោក នេត្រ ភក្ត្រា រដ្ឋលេខាធិការ និងជាមន្ត្រីនាំពាក្យក្រសួងបរិស្ថាន បានលើកឡើងថា បច្ចុប្បន្នក្រសួងបាននឹងកំពុងអនុវត្តសកម្មភាពសំខាន់ៗចំនួន៤ គឺ ការអភិរក្សជីវៈចម្រុះ ការលើកម្ពស់ជីវភាពសហគមន៍ ការអប់រំផ្សព្វផ្សាយ និងការសិក្សាស្រាវជ្រាវ។

លោក នេត្រ ភក្ត្រា បានថ្លែងថា៖ «ចំពោះការអភិរក្សជីវៈចម្រុះ យើងបានសាងសង់ស្នាក់ការរងចំនួន១កន្លែងសម្រាប់ពង្រឹងការល្បាតនៅក្នុងតំបន់ សាងសង់អាងទឹកទំហំ ១៦ហិកតាដើម្បីរក្សាទឹកទុកជាអចិន្ត្រៃយ៍សម្រាប់ទ្រទ្រង់ដល់ពពួកសត្វស្លាបទឹកជាពិសេសសត្វក្រៀល»។

លោកថា ក្រុមការងារក៏បានធ្វើការដាំព្រៃលិចទឹកទំហំ៥ហិកតា និងដាំម៉ឺមផ្លុងទំហំ២៥ហិកតា ដែលជាចំណីរបស់សត្វក្រៀល និងបានគ្រប់គ្រងរុក្ខជាតិប្រភេទរាតត្បាត ដូចជាប្រខ្លបយក្ស (Mimosa pigra) វល្លិ៍រាតត្បាត និងកំប្លោក ជាដើម។

រីឯសកម្មភាពលើកម្ពស់ជីវភាពសហគមន៍វិញ បានបង្កើតធនាគារក្របី ដោយធ្វើការប្រវាស់ក្របីជាមួយប្រជាសហគមន៍មូលដ្ឋាន នៅក្នុងតំបន់ការពារទេសភាពបឹងព្រែកល្ពៅ។ ចំណែកឯ ការអប់រំផ្សព្វផ្សាយ យើងបានបញ្ចូល កម្មវិធីអប់រំបរិស្ថាននិងសត្វក្រៀលជាមួយសាលារៀនគោលដៅចំនួន។

លោក នេត្រ ភក្ត្រា បានបញ្ជាក់ថា សាលាទាំងនោះមានសាលាបឋមសិក្សាសង្គមមានជ័យ សាលាបឋមសិក្សាគ្គុលជ្រុំ និងសាលាបឋមសិក្សាបន្ទាយធ្លាយ ដើម្បីលើកកម្ពស់ការយល់ដឹងរបស់សិក្សានុសិស្សអំពីសារៈសំខាន់ជីវៈចម្រុះ ជាពិសេសសត្វក្រៀលនៅក្នុងតំបន់ការពារទេសភាពបឹងព្រែកល្ពៅ។ លោកបានថ្លែងថា ៖ «យើងក៏មានកម្មវិធីផ្សព្វផ្សាយតាមទម្រង់ផ្សេងៗទៀតដូចជាការចាក់បញ្ចាំងខ្សែភាព យន្ត អប់រំ និងការចាក់សំឡេងចល័ត នៅតាមភូមិជាប់នឹងតំបន់ការពារទេសភាពនេះផងដែរ។ ដោយឡែកការសិក្សាស្រាវជ្រាវវិញ យើងបាននឹងកំពុងធ្វើការសិក្សាវាយតម្លៃលើសេវាកម្មប្រព័ន្ធអេកូឡូស៊ី និងការសិក្សាអំពីប្រព័ន្ធជលសាស្រ្តនៅតំបន់នោះ»។

ដោយសារកិច្ចខំប្រឹងប្រែងរបស់អ្នកពាក់ព័ន្ធទាំងអស់គ្នា ទើបធ្វើឱ្យតំបន់នេះមានការកើនឡើងនូវប្រភេទជីវៈចម្រុះមួយចំនួនជាពិសេសសត្វចង្កៀលខ្យងដែលកើនឡើងរហូតដល់រាប់ពាន់ក្បាល និងមានសម្បុកពងកូនយ៉ាងតិចចំនួន២១៨៦ ក្នុងឆ្នាំ២០២០ ខណៈពួកវាមានចំនួនជាង១០០ក្បាលប៉ុណ្ណោះកាលពីឆ្នាំ២០០៣ ។

លើសពីនេះទៅទៀត ក៏ឃើញមានវត្តមានប្រភេទសត្វស្លាបជិតផុតពូជដូចជាសត្វចាបព្រៃវែង និងត្រដក់ធំ។

លោក ស្រី ស៊ុនលាង អគ្គនាយករងនៃអគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ នៃក្រសួងបរិស្ថានបានលើកឡើងផងដែរថា ក្នុងនាមជាប្រទេសហត្ថលេខីនៃអនុសញ្ញារ៉ាមសារ ក្រសួងបរិស្ថានតែងតែចូលរួមអនុវត្តនូវសសរស្តម្ភទាំង៣របស់អនុសញ្ញារ៉ាមសារ។

លោកស្រីថា ៖ «សសរស្តម្ភទាំង៣មាន ការប្រើប្រាស់តំបន់ដីសើមដោយឈ្លាសវៃ ការកំណត់ និងបង្កើតតំបន់រ៉ាមសារថ្មីៗ និងកិច្ចសហប្រត្តិបតិការអន្តរជាតិ ជាពិសេសការគ្រប់គ្រងតំបន់ដីសើមឆ្លងដែន»។

ចំណែក លោក ប៊ូ វរសក្ស តំណាងឱ្យអង្គការជីវិតធម្មជាតិនៅកម្ពុជា អង្គការជីវិតសត្វស្លាបអន្តរជាតិ និងអង្គការ The Wildfowl & Wetlands Trust ក៏បានលើកឡើងថា លោកពិតជាមានមោទភាពណាស់ដែលបានចូលរួមជាមួយក្រសួងបរិស្ថានក្នុងការការពារ និងអភិរក្សជីវៈចម្រុះនៅក្នុងតំបន់ការពារទេសភាពបឹងព្រែកល្ពៅនេះ។

លោកមានប្រសាសន៍ថា៖ «យើងខ្ញុំទាំងអស់គ្នានេះ នឹងបន្តគាំទ្រការងារអភិរក្សតំបន់ដីសើមដ៏មានសក្តានុពលនេះ ឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។ ជាមួយគ្នានេះ លោកបានស្នើសុំឱ្យក្រសួងបរិស្ថាន និងអាជ្ញាធរថ្នាក់ក្រោមជាតិ បន្តពង្រឹងការអនុវត្ត ច្បាប់ និងពន្លឿននីតិវិធីក្នុងការបែងចែកតំបន់គ្រប់គ្រងនៅក្នុងតំបន់នេះ»។

ទាក់ទងនឹងការស្នើនេះ លោក នេត្រ ភក្ត្រា បានបញ្ជាក់ថា ក្រសួងនឹងចាត់វិធានការច្បាប់ចំពោះជនទាំងឡាយណាដែលរំលោភបំពានទន្ទ្រានយកដីដោយខុសច្បាប់នៅតំបន់ការពារទេសភាពបឹងព្រែកល្ពៅ។

លោកថ្លែងថា ៖ «គ្មានជនណាម្នាក់មានសិទ្ធិ ទិញលក់ដូរដីក្នុងតំបន់អភិរក្សបានឡើយ ហើយក្រសួង បរិស្ថានបដិសេធទទួលស្គាល់នូវលិខិតទិញដូរខុសច្បាប់ទាំងអស់»។

ជាមួយគ្នានេះ អនុប្រធានមន្ទីរបរិស្ថានខេត្តតាកែវ លោក ហុង ភារៈ បានលើកឡើងថា មន្ទីរបរិស្ថានខេត្តតាកែវ បានយកចិត្តទុកដាក់នៅក្នុងការពារថែរក្សាអភិរក្សជីវៈចម្រុះ នៅតំបន់ការពារទេសភាពបឹងព្រែកល្ពៅនេះ។

លោកបន្តថា មន្ត្រីឧទ្យានុរក្សប្រចាំការ និងចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូនានាក្នុងការការពារអភិរក្ស និងអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីច្បាប់ និងតម្លៃនៃប្រព័ន្ធអេកូឡូស៊ីរបស់តំបន់ការពារទេសភាពបឹងព្រែកល្ពៅ៕



# ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍអន្តរជាតិ USAID ប្រកាសអំពីភាពជាដៃគូដើម្បីជំរុញកំណើនសេដ្ឋកិច្ចនៅកម្ពុជា




*អត្ថបទ៖ ផល សុផានិត*

ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍអន្តរជាតិ USAID បានប្រកាសភាពជាដៃគូថ្មីជាមួយក្រុមហ៊ុន ឯកជនចំនួនពីរ ដើម្បីវិនិយោគរួមគ្នាលើច្រវ៉ាក់ផ្គត់ផ្គង់ត្រជាក់ (cold chain) សមត្ថភាពផ្ទុក ផលិតផលកសិកម្ម និង ភស្តុភារនៅកម្ពុជា។ ភាពជាដៃគូនេះ នឹងជំរុញការប្រកួតប្រជែង សេដ្ឋកិច្ចរ បស់ប្រទេសនិងបរិយាបន្នដោយបំពេញនូវចន្លោះប្រហោង នៃច្រវ៉ាក់ផ្គត់ផ្គង់ក្នុងវិស័យកសិកម្ម ។

ក្រុមហ៊ុនខ្មែរខូលឆេន ឯ.ក. (Khmer Cold Chain ) និងក្រុមហ៊ុន Amru Rice នឹងបង្កើត ធ្វើតេស្ត និងដំណើរការកន្លែងទុកដាក់ត្រជាក់ សេវាកម្មនិងសមត្ថភាពដឹកជញ្ជូនកសិកម្មនៅកម្ពុជា ដោយបង្កើតនូវ ច្រវ៉ាក់ផ្គត់ផ្គង់ដែលមានសុវត្ថិភាព និងមានការគ្រប់គ្រងដោយសីតុណ្ហភាព។ ភាពជាដៃគូនេះ នឹងដោះស្រាយឧបសគ្គនៃប្រព័ន្ធទីផ្សារចំពោះឱកាសនាំចេញនិងនាំចូល ដោយផ្តោតការយកចិត្តទុកដាក់ ទៅលើការធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពជ្រៀតចូលទីផ្សារសម្រាប់កសិករខ្នាតតូច និងធុរកិច្ចដែលដឹកនាំដោយស្ត្រីនិងយុវជន។

លោកស្រី Nancy J. Eslick នាយិកានៃទីភ្នាក់ងារជំនួយអាមេរិក USAID មានប្រសាសន៍ថា "ភាពជាដៃគូរបស់ USAID ជាមួយក្រុមហ៊ុនកម្ពុជា គឺជួយកាត់បន្ថយហានិភ័យផ្នែកហិរញ្ញវត្ថុ ដូចនេះពួកគេអាច ធ្វើតេស្តនិងលើកកម្ពស់ដំណោះស្រាយជោគជ័យ ព្រមទាំងជំរុញការ វិនិយោគលើវិស័យកសិកម្ម ដើម្បីបង្កើនសមាហរណកម្មពាណិជ្ជកម្មក្នុងតំបន់និងអន្តរជាតិ"

ក្នុងភាពជាដៃគូរយៈពេល២ឆ្នាំនេះ ក្រុមហ៊ុនខ្មែរខូលឆេន ឯ.ក. ដែលជាក្រុមហ៊ុនបម្រើសេវាកម្មការ ភស្តុភារទុកដាក់ត្រជាក់ នឹងចូលរួមវិនិយោគមូលនិធិរបស់ខ្លួនចំនួនប្រមាណ ១លានដុល្លា សហរដ្ឋអាមេរិក និងបូករួមបន្ថែមមូលនិធិពីរដ្ឋាភិបាលសហរដ្ឋអាមេរិកនិងវិស័យឯកជនប្រមាណ ១លានដុល្លា បន្ថែមទៀត ដើម្បីដំណើរការប្រព័ន្ធទុកដាក់ត្រជាក់ ដែលផ្តល់ឱ្យកសិករទទួលបាន តម្លៃប្រសើរជាងមុ នពីទំនិញរបស់ពួកគេ ឱ្យពួកគេអាចលក់ផលិតផលទៅកាន់អន្តរជាតិ និងធានាថាអ្នកប្រើប្រាស់ ទទួលបាននូវទំនិញប្រកបដោយគុណភាពខ្ពស់។

ក្រុមហ៊ុន Amru Rice ដែលជាក្រុមហ៊ុនផលិតចំណីអាហារនិងជាពាណិជ្ជករដែលនាំចេញកសិផល ដូចជា អង្ករ ដំឡូងមី ស្វាយច័ន្ទី និងម្រេច នឹងវិនិយោគដោយប្រើប្រាស់ទុនផ្ទាល់ខ្លួនចំនួនប្រមាណ ៦សែនដុល្លាអាមេរិក និងបូករួមមូលនិធិរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិកចំនួនប្រមាណ ៤សែនដុល្លា បន្ថែមទៀត ដើម្បីបង្កើតបន្ទប់រក្សាទុកត្រជាក់នៅជិតការិយាល័យកណ្តាលរបស់ខ្លួន និងនៅជិតបណ្តាសហគមន៍អភិវឌ្ឍន៍កសិកម្ម ដោយបង្កើតកន្លែងទុកដាក់ត្រជាក់និងបណ្តាញ ភស្តុភារដល់អ្នកផ្គត់ផ្គង់កសិករ ខ្នាតតូច។ វិធីសាស្ត្រប្រកបដោយភាពច្នៃប្រឌិត ចំពោះច្រវ៉ាក់ផ្គ ត់ផ្គង់បន្លែនេះ នឹងបង្កើនសក្តានុពលរបស់កសិករកម្ពុជា ក្នុងការផលិតកសិផលប្រកបដោយគុណភាព ដើម្បីផ្គត់ផ្គង់ទីផ្សារក្នុងស្រុកនិងអន្តរជាតិ ក្នុងគោលបំណងកែលម្អសន្តិសុខស្បៀង បង្កើនប្រាក់ ចំណូលដល់ កសិករផលិត និងកាត់បន្ថយការពឹងផ្អែករបស់កម្ពុជាលើការ នាំចូលបន្លែពីក្រៅប្រទេស ។

> ភាពជាដៃគូរបស់ USAID ជាមួយក្រុមហ៊ុនកម្ពុជា គឺជួយកាត់បន្ថយហានិភ័យផ្នែកហិរញ្ញវត្ថុ ដូចនេះពួកគេអាច ធ្វើតេស្តនិងលើកកម្ពស់ដំណោះស្រាយជោគជ័យ ព្រមទាំងជំរុញការ វិនិយោគលើវិស័យកសិកម្ម ដើម្បីបង្កើនសមាហរណកម្មពាណិជ្ជកម្មក្នុងតំបន់និងអន្តរជាតិ



សហវិនិយោគរបស់ទីភ្នាក់ងារ USAID មានគោលបំណងពង្រីកការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ទៅដល់គ្រួសារកសិករតាមទីជនបទ ដែលងាយរងគ្រោះពីកង្វះសន្តិសុខស្បៀង ដោយសារការចូល ទៅកាន់ ទីផ្សារផ្លូវការក្នុងប្រទេសកម្ពុជា និងក្រៅប្រទេសមានកម្រិត។ ទីភ្នាក់ងារ USAID ប្រចាំកម្ពុជា ប្តេជ្ញាក្នុងការសម្របសម្រួលភាពជាដៃគូ និងសកម្មភាពនានាដែលបង្កើនការលក់និងឱកាសការងារ ក្នុងវិស័យកសិកម្មនៅកម្ពុជា៕

# សម្តេចតេជោ ហ៊ុន សែន៖ «យើងគ្មានតម្រូវការបិទប្រទេស ដោយសារកូវីដទៀតទេ»

*អត្ថបទ៖ ផល សុផានិត*

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា នៅថ្ងៃទី ២២ ខែកុម្ភៈ បានប្រកាសថា រាជរដ្ឋាភិបាលកម្ពុជាគ្មានតម្រូវការត្រូវបិទទីក្រុង ឬខេត្ត ដោយសារកូវីដ-១៩ទៀតនោះទេ។ការប្រកាសនេះ សម្តេចចង់ឆ្លើយតបទៅនឹងមតិលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជាអាចនឹងបិទក្រុងឡើងវិញ ខណៈជំងឺកូវីដអូមីក្រុងឆ្លងច្រើននៅកម្ពុជា។

សម្តេចតេជោ ហ៊ុន សែន បានទទួលស្គាល់ថា ក្នុងរយៈពេលចុងក្រោយនេះចំនួនអ្នកឆ្លងកូវីដបំប្លែងខ្លួនថ្មីប្រភេទអូមីក្រុងឆ្លងច្រើននៅក្នុងសហគមន៍នៅកម្ពុជា។តែសម្តេច បានប្រកាសរាជរដ្ឋាភិបាលមិនមានគោលការណ៍ណាមួយដែលត្រូវបិទទីក្រុង ឬខេត្តណាមួយដោយសារកូវីដ-១៩ទៀតនោះទេ។

បើតាមសម្តេចតេជោ ហ៊ុន សែន ប្រសិនបើមានករណីឆ្លងកូវីដក្នុងតំបន់ណា តំបន់នោះអាចរៀបចំបិទ ឬផ្អាកបណ្តោះអាសន្នតាមទីតាំងជាក់ស្តែង ដោយអនុវត្តតាមវិធានការសុខាភិបាលដែលបានប្រកាសដាក់ចេញដោយក្រសួងសុខាភិបាលកម្ពុជា។ម្យ៉ាងវិញទៀត ពលរដ្ឋកម្ពុជាបានទទួលចាក់វ៉ាក់សាំងស្ទើរគ្រប់គ្នា ដូច្នេះបើទោះបីឆ្លងក៏ជំងឺនេះស្រាលពលរដ្ឋអាចព្យាបាលនៅតាមផ្ទះរបស់ខ្លួនបានតាមការណែនាំរបស់ក្រសួង។

តែយ៉ាងណា សម្តេចតេជោ ហ៊ុន សែន បានអំពាវនាវដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់កុំមើលស្រាលជំងឺកូវីដបំប្លែងខ្លួនថ្មីប្រភេទអូមីក្រុងនេះ ព្រោះនៅរយៈពេល៣ថ្ងៃចុងក្រោយនេះ កម្ពុជាចាប់ផ្តើមមានអ្នកស្លាប់ដោយសារកូវីដ-១៩ចាប់តាំងពីជំងឺនេះវាយចូលក្នុងសហគមន៍កម្ពុជា។ ដូច្នេះតម្រូវឱ្យប្រជាពលរដ្ឋកម្ពុជាទាំងអស់ត្រូវតែអនុវត្តតាមវិធានការណែនាំរបស់ក្រសួងសុខាភិបាល ៣កុំ ៣ការពារ៕



## គម្រោង អភិវឌ្ឍន៍ជំនាញការងារឌីជីថល ត្រូវបានប្រកាសអនុវត្តជាផ្លូវការ




*អត្ថបទ៖ ផល សុផានិត*

គម្រោងផ្តួចផ្តើមថ្មីមួយដែលមានមូលនិធិ ១៥ លានដុល្លារអាមេរិក ផ្តល់ដោយទីភ្នាក់ងារជំនួយអាមេរិក USAID ក្នុងគោលបំណងផ្តល់ឱ្យយុវជនកម្ពុជានូវជំនាញក្នុងការប្រកួតប្រជែងលើវិស័យសេដ្ឋកិច្ចឌីជីថល ត្រូវបានដាក់ឱ្យអនុវត្តកាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ ។

សាកលវិទ្យាល័យកាលីហ្វ័រញ៉ានៅទីក្រុងប៊ឺកលី នឹងអនុវត្តគម្រោង «អភិវឌ្ឍន៍ជំនាញការងារឌីជីថល» រយៈពេលប្រាំឆ្នាំរួមជាមួយនឹងស្ថាប័នដៃគូកម្ពុជាជាច្រើន។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ទីភ្នាក់ងារជំនួយអាមេរិក USAID បានឱ្យដឹងថា គម្រោងនេះនឹងពង្រឹងជំនាញឌីជីថលរបស់យុវជននិងអ្នកជំនាញរបស់កម្ពុជា ដើម្បីឱ្យប្រទេសនេះអាចពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់ខ្លួននៅក្នុងសេដ្ឋកិច្ចពិភពលោក ដែលពឹងផ្អែកលើបច្ចេកវិទ្យាកាន់តែខ្លាំង និងត្រូវការជំនាញការងារឌីជីថល។

USAID បានបញ្ជាក់ថា ៖ «គម្រោងថ្មីនេះនឹងធ្វើការជាមួយគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា ដើម្បីពង្រឹងវគ្គសិក្សា និងកម្មវិធីនានាសម្រាប់ និស្សិតក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។ វាក៏នឹងជួយស្ថាប័នទាំងនោះឱ្យបំពេញតាមស្តង់ដារ អប់រំដែលមានការទទួលស្គាល់ ដូច្នេះនិយោជកអាចជ្រើសរើសនិស្សិតបញ្ចប់ការសិក្សានៅកម្ពុជាដោយមានទំនុកចិត្ត»។

អាហារូបករណ៍និងឱកាសបង្កើតបណ្តាញ នឹងជាអាទិភាពមួយសម្រាប់គម្រោងថ្មីនេះ ដើម្បី ឱ្យនិស្សិត និង យុវជនកម្ពុជាអាចកសាងជំនាញ និងស្វែងរកឱកាសការងារដែលត្រូវនឹងការអប់រំរបស់ពួកគេ។

គម្រោងនេះក៏នឹងតភ្ជាប់វិស័យឯកជនរបស់កម្ពុជា និងសាកលវិទ្យាល័យក្នុងស្រុកជាច្រើន ដោយបង្កើតឱកាស ការងារតាមរយៈការចុះកម្មសិក្សា ក្នុងកិច្ចសហការជាមួយវិស័យឯកជន។ គម្រោងនេះនឹងផ្តល់អាទិភាពខ្ពស់លើ បរិយាប័ន្ន ដើម្បីធានាថាយុវជនមកពីគ្រប់មជ្ឈដ្ឋានអាចទទួលបានឱកាសដែលគម្រោងនេះនឹងផ្តល់ឱ្យ៕

## អ្នកស្ម័គ្រចិត្តចៃកា (JICA) ថ្មីចំនួន ៣នាក់ បានមកដល់ប្រទេសកម្ពុជា

*អត្ថបទ៖ អមរិន្ទ ដានុត*

អ្នកស្ម័គ្រចិត្តចៃកា (JICA) ថ្មីចំនួន ៣នាក់ បានមកដល់ប្រទេសកម្ពុជា ក្រោមកម្មវិធីអ្នកស្ម័គ្រចិត្តសហប្រតិបត្តិការជប៉ុននៅក្រៅប្រទេស (JOCV) របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន។ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មានស្តីពីស្ពានឆ្ពោះទៅអនាគត-អ្នកស្ម័គ្រចិត្តចៃកាជាមួយនឹងប្រជាជនកម្ពុជាក្នុងអំឡុងពេលរីករាលដាលនៃជំងឺកូវីដ-១៩ ។

សេចក្តីប្រកាសព័ត៌មាន នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ ២០២២នេះ បានឱ្យដឹងថា អ្នកស្ម័គ្រចិត្តថ្មីទាំង៣នាក់នេះនឹងត្រូវបញ្ជូនទៅធ្វើការផ្នែកថែទាំជំងឺ និងអប់រំបឋមសិក្សា នៅខេត្តក្រចេះ និងកំពង់ឆ្នាំង។ ខណៈពេលរង់ចាំការបញ្ជូនពួកគេបានសិក្សាភាសាខ្មែរ មិនត្រឹមតែសិក្សានៅប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែក៏នៅប្រទេសជប៉ុនផងដែរ។

នៅមន្ទីរពេទ្យបង្អែកខេត្តក្រចេះ អ្នកស្ម័គ្រចិត្តចៃកានឹងធ្វើការជាមួយប្រធានមន្ទីរពេទ្យ និងគិលានុបដ្ឋាយិកាក្នុងការគាំទ្រការបែងចែកការផ្តល់សេវាព្យាបាលដំបូងជូនអ្នកជំងឺ និងលើកកម្ពស់ការគ្រប់គ្រងការឆ្លងមេរោគ ដើម្បីធ្វើឱ្យមន្ទីរពេទ្យកាន់តែមានភាពកក់ក្តៅ និងគួរជាទីទុកចិត្តសម្រាប់ប្រជាជនក្នុងតំបន់។

សេចក្តីប្រកាសព័ត៌មានរបស់JICA បានឱ្យដឹងថា ៖ «នៅសាលាបឋមសិក្សា អ្នកស្ម័គ្រចិត្តចៃកានឹងធ្វើការដោយសហការជាមួយនាយកនិងនាយិកាសាលា និងលោកគ្រូ-អ្នកគ្រូ ដើម្បីគាំទ្រសិស្សផ្នែកអប់រំកាយ និងតន្ត្រី។ មុខវិជ្ជាទាំងនេះ គឺថ្មីនៅក្នុងប្រទេសកម្ពុជា»។

លើសពីនេះ អ្នកស្ម័គ្រចិត្តចៃកា នឹងរៀបចំសិក្ខាសាលាសម្រាប់គ្រូដើម្បីអនុវត្តជំនាញ និងកែលម្អវិធីសាស្ត្របង្រៀនសម្រាប់មុខវិជ្ជាទាំងនោះ។ នេះគឺជាការចាប់ផ្តើមនៃសកម្មភាពជាថ្មីសម្រាប់អ្នកស្ម័គ្រចិត្តចៃកា បន្ទាប់ពីការបើកដំណើរការសកម្មភាពសេដ្ឋកិច្ច-សង្គមរបស់ប្រទេសឡើងវិញ ប៉ុន្តែវាមិនមែនជាការចាប់ផ្តើមកម្មវិធី JOCV ឡើងវិញទេនោះទេ។

ប្រភពដដែលថា JOCVs បាន និងកំពុងធ្វើការជាបន្តបន្ទាប់នៅក្នុងប្រទេសកម្ពុជា និងតស៊ូជាមួយគ្នាក្នុងអំឡុងពេលជួបការលំបាកដោយសារការរីករាលដាលជំងឺកូវីដ-១៩ នៅក្នុងឆ្នាំ ២០២០ និង២០២១ ។

ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ នៅខែមីនាឆ្នាំ ២០២០ JOCVs ត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសជប៉ុនវិញ។ ទោះស្ថិត ក្នុងប្រទេសជប៉ុនក៏ដោយ JOCVs បានបន្តការងាររបស់ពួកគេរហូតដល់ទីបញ្ចប់ ក្នុងការធ្វើការជាមួយមិត្តរួមការងារកម្ពុជា ដោយផ្តល់ការគាំទ្រពីចម្ងាយតាមប្រព័ន្ធអ៊ីនធឺណិត។

គួរបញ្ជាក់ថា នៅ ខែធ្នូ ឆ្នាំ ២០២០ JOCV ចំនួន៦នាក់បានត្រលប់មកកម្ពុជាវិញ ហើយបន្ទាប់មកនៅឆ្នាំ ២០២១ JOCV ចំនួន ៥រូប ទៀតក៏បានត្រលប់មកកម្ពុជាវិញផងដែរ។ តាមរយៈសកម្មភាពតាមប្រព័ន្ធអនឡាញ ពួកគេអាចជម្នះការលំបាករួមគ្នាជាមួយប្រជាជនកម្ពុជា ហើយសូម្បីតែបច្ចុប្បន្ននេះ អ្នកស្ម័គ្រចិត្តមួយចំនួននៅតែបន្តការងាររបស់គេនៅក្នុងប្រទេសកម្ពុជា ហើយកំពុងធ្វើការផ្នែកអប់រំវិទ្យាសាស្ត្រ និងការលើកកម្ពស់បរិយាកាសមន្ទីរពេទ្យឲ្យកាន់តែល្អប្រសើរជាដើម។

កម្មវិធី JOCV នៅកម្ពុជាបានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៦៥ ដោយមានប្រវត្តិ៥៧ឆ្នាំមកហើយ ហើយអ្នកស្ម័គ្រចិត្តប្រមាណជាង ៨០០នាក់ ត្រូវបានបញ្ជូនមកប្រទេសកម្ពុជា។ JOCVs តែងតែនៅជាមួយប្រទេសកម្ពុជា និងប្រជាជនកម្ពុជាជានិច្ច។ ទោះបីជាស្ថិតក្រោមការរាតត្បាតនៃជំងឺកូវីដ-១៩ក៏ដោយ JICA នៅតែបន្តធ្វើការរួមគ្នាជាមួយប្រជាជនកម្ពុជា ហើយយើងរួមគ្នាឆ្ពោះទៅរកការអភិវឌ្ឍប្រទេសកម្ពុជា៕

# រាជរដ្ឋាភិបាលកំណត់ខេត្តចំនួន៥ ក្លាយជាខេត្តដែលបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល «ODF» នៅឆ្នាំ២០២៣ ខណៈខេត្តខ្លះបានសម្រេចមុនកាលកំណត់



*អត្ថបទ៖ អមរិន្ទ ដានុត*

ស្រុកខ្លះនៃខេត្តមួយចំនួននៅទូទាំងប្រទេសកម្ពុជា បានចាប់ផ្តើមសម្រេចបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល «ODF» ជាបណ្តើរៗផង ដោយក្នុងនោះមានខេត្តចំនួនមួយបានប្រកាសសម្រេចបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលហើយផងដែរ គឺខេត្តស្វាយរៀង។

ជាមួយគ្នានេះដែរ ក្រសួងអភិឌ្ឍន៍ជនបទក៏បានកំណត់យកខេត្តចំនួន ៥ ឱ្យក្លាយជាខេត្តដែលបញ្ឈប់ការ បន្ទោបង់ពាសវាលពាសកាលនៅឆ្នាំ២០២៣ផងដែរ ក្នុងនោះរួមមាន ខេត្តកំពង់ស្ពឺខេត្តកំពង់ឆ្នាំង ខេត្ត កែប ខេត្ត ព្រៃវែង និងខេត្តស្វាយរៀង។

លោក ជុំ ហាត ប្រធានក្រុមប្រឹក្សាខេត្ត បានលើកឡើងកាលពីដើមខែកុម្ភៈ ថា នៅទូទាំងខេត្តស្វាយរៀងគិតត្រឹមដើមឆ្នាំ២០២២នេះ ដោយខេត្តនេះបានសម្រេច ១០០ ភាគរយនៃអត្រាគ្របដណ្តប់អនាម័យនៃការបញ្ឈប់បន្ទោបង់ពាសវាលពាសកាល តាមរយៈការព្រោបការយល់ដឹង និងអប់រំលើកកម្ពស់អនាម័យនៅតាមជនបទ។

លោកបានប្រសាសន៍ថា៖«តាមរយៈការយកចិត្តទុកដាក់ពីក្រុមប្រឹក្សាខេត្តគណៈអភិបាលខេត្ត និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្តបានអនុវត្តសកម្មភាពអប់រំលើកកម្ពស់អនាម័យជនបទ ប្រជាពលរដ្ឋបានយល់ដឹងពីសារៈសំខាន់នៃទម្លាប់អនាម័យល្អប្រចាំថ្ងៃ»។

ទម្លាប់តាមរយៈការប្រតិបត្តិអនាម័យល្អ ៣ យ៉ាងគឺ បន្ទោបង់ក្នុងបង្គន់ ហូបទឹកស្អាត និងលាងដៃជាមួយសាប៊ូ ជាហេតុធ្វើឱ្យស្ថានភាពអនាម័យទូទាំងខេត្តស្វាយរៀង រីកចម្រើនបានល្អប្រសើរយ៉ាងឆាប់រហ័ស។ នេះជាការបញ្ជាក់បន្ថែមរបស់លោក ជុំ ហាត។

គួរបញ្ជាក់ថា ខេត្តស្វាយរៀង មាន២ក្រុង ៦ស្រុក ៦៨ឃុំ ១២សង្កាត់ និង៦៩០ ភូមិ ដែលមានប្រជាពលរដ្ឋសរុបចំនួន ៦៥៣ ៧៦៦ នាក់។

ជាមួយគ្នានេះដែរស្រុកចំនួន ០៤ ក្នុងចំណោមក្រុង-ស្រុកទាំង១១ របស់ខេត្តកណ្តាល ត្រូវបានសម្រេចជាស្រុកដែលបញ្ឈប់ការបន្ទោបង់ពាសវាល ពាសកាល «ODF» និងបានប្រកាសទទួលស្គាល់ជាផ្លូវការដោយក្រសួងអភិវឌ្ឍន៍ជនបទកាលពីដើមខែកុម្ភៈកន្លងទៅនេះផងដែរ។

ស្រុកចំនួន ០៤ នោះរួមមាន ស្រុកអង្គស្នួល ស្រុកកណ្តាលស្ទឹង ស្រុកខ្សាច់កណ្តាល និងស្រុកលើកដែក។

លោក គង់ សោភ័ណ្ឌ អភិបាលខេត្តកណ្តាលក៏បានលើកឡើងដែរថា ការលើកកម្ពស់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ តាមរយៈក្រសួង អភិវឌ្ឍន៍ជនបនបទ បានជួយឱ្យប្រជាពលរដ្ឋនៅតំបន់ជនបទ មានទឹកស្អាតប្រើប្រាស់ មានអនាម័យស្អាត មានបរិស្ថានល្អ មានបង្គន់អនាម័យប្រើប្រាស់ កាត់បន្ថយជំងឺឆ្លងតាមរយៈទឹកមិនស្អាត ឬបន្ទោបង់ដែលបានជួយសន្សំសំចៃថវិកាផងដែរ។

លោក គង់ សោភ័ណ្ឌក៏បានស្នើដល់អភិបាលក្រុង-ស្រុក ចំនួន៧ទៀត និងមេឃុំចៅសង្កាត់ ត្រូវចូលរួមសហការ និងអនុវត្តឱ្យបានពេញលេញ និងច្បាស់លាស់ យកចិត្តទុកដាក់ ឱ្យបានខ្លាំងក្លាជំរុញ ដល់ថ្នាក់ដឹកនាំភូមិ ដែលជាជនបង្គោលភូមិ និងត្រូវផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យពួកគាត់បានដឹង និងចូលរួមសហការ ធ្វើយ៉ាងណាឱ្យខេត្តកណ្តាលសម្រេចបាន ODF ទូទាំងខេត្តនៅឆ្នាំ២០២២ ។






> តាមរយៈការយកចិត្តទុកដាក់ពីក្រុមប្រឹក្សាខេត្តគណៈអភិបាលខេត្ត និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្តបានអនុវត្តសកម្មភាពអប់រំលើកកម្ពស់អនាម័យជនបទ ប្រជាពលរដ្ឋបានយល់ដឹងពីសារៈសំខាន់នៃទម្លាប់អនាម័យល្អប្រចាំថ្ងៃ

សម្រាប់ខេត្តកណ្តាល គ្រួសារដែលមានទឹកស្អាតប្រើប្រាស់មានចំនួន ៨៤.១% និងគ្រួសារទំលាប់ទទួលទានទឹកស្អាត មាន ៩៤.៧%។ នេះបើតាមការឱ្យដឹងពីប្រធានមន្ទីរអភិវឌ្ឍន៍ខេត្តកណ្តាល លោកស្រី ជី ថាវី។

លោកស្រីថា ចំពោះស្ថានភាពអនាម័យ ខ្នងផ្ទះមានបង្គន់អនាម័យប្រើ មាន ៩៥% ឯខ្នងផ្ទះប្រើបង្គន់រួមមាន ៤.៥% ចំណែកខ្នងផ្ទះដែលគ្មានបង្គន់អនាម័យប្រើ មាន ០.៥% ស្មើនឹង ១,៣៥១ខ្នងផ្ទះទៀតតែប៉ុណ្ណោះ។

លោកស្រី ជី ថាវី បានបញ្ជាក់ថា ៖ «ចំពោះស្រុកបានបញ្ឈប់បន្ទោបង់ពាសវាលពាសកាល(ODF) បច្ចុប្បន្នសម្រេចបានចំនួន ៤ស្រុក ៥៣ឃុំ និង៤៤៥ភូមិ»។

ស្រដៀងគ្នានេះដែរ នៅក្នុងខេត្តរតនគិរី ក៏បានប្រកាសទទួលស្គាល់ស្រុកមួយក្នុងចំណោមក្រុងស្រុកទាំង៨ ពីការបញ្ឈប់ការបន្ទោបង់ពាសវាសពាសកាលផងដែរ។

លោក ញ៉ែម សំអឿន អភិបាលខេត្តរតនគិរី បានឱ្យដឹងថា រហូតដល់ឆ្នាំ២០២១នេះ ខេត្តរតនគិរីមានភូមិដែលបញ្ឈប់ការបន្ទោបង់ ពាសវាលពាសកាល មានចំនួន៣៧ភូមិ និងឃុំដែលបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាលមានចំនួន៧ឃុំ និងស្រុកបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាលមានចំនួន១ស្រុក ក្នុងនោះផងដែរ។

លោកបានប្រាប់ថា ៖ «ស្រុកអូរជុំគឺជាស្រុក










ទីមួយដែលទទួលបានជ័យលាភី សម្រេចបាន ស្រុកបញ្ឈប់ ការបន្ទោបង់ពាសវាលពាសកាល នៅពាក់កណ្តាលឆ្នាំ២០២១នេះ»។ «នេះគឺជាផ្នែកមួយដ៏សំខាន់ ដែលរដ្ឋបាលខេត្តបាននឹងកំពុងយកចិត្តទុកដាក់ ពោលគឺធ្វើយ៉ាងណាឲ្យការផ្គត់ផ្គង់សេវាផ្នែកនេះ បានផ្តល់ដល់ដៃប្រជាពលរដ្ឋ»។

អភិបាលខេត្តរូបនេះ បានបន្ថែម៖ «និយាយរួមគឺសម្រេចបាននូវទិសដៅរបស់រដ្ឋាភិបាលកម្ពុជា ឆ្នាំ២០២៣ អត្រាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យឲ្យបាន៩០% និងទស្សនវិស័យនៅឆ្នាំ២០២៥ ប្រជាជនគ្រប់រូប នៅសហគមន៍ជនបទ ត្រូវតែមានការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថាន ដែលមានអនាម័យប្រកបដោយនិរន្តរភាព»។

> នេះគឺជាផ្នែកមួយដ៏សំខាន់ ដែលរដ្ឋបាលខេត្តបាននឹងកំពុងយកចិត្តទុកដាក់ ពោលគឺធ្វើយ៉ាងណាឲ្យការផ្គត់ផ្គង់សេវាផ្នែកនេះ បានផ្តល់ដល់ដៃប្រជាពលរដ្ឋ

ការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ រាជរដ្ឋាភិបាលបាននិងមានគោលដៅយ៉ាងច្បាស់លាស់នៅក្នុងគោលនយោបាយជាតិស្តីពីកំណត់នូវទស្សនៈវិស័យ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទនេះ។ នេះបើតាមរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ លោក អ៊ុក រ៉ាប៊ុន។

លោកបានថ្លែងថា ៖ «គោលនយោបាយជាតិស្តីពីកំណត់នូវទស្សនៈវិស័យ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទនេះគឺ នៅឆ្នាំ២០២៥ ប្រជាពលរដ្ឋគ្រប់រូប ព្រមទាំងរស់នៅក្នុងនៅសហគមន៍ជនបទ ត្រូវមានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ បរិស្ថានដែលមានអនាម័យស្អាតប្រកបដោយនិរន្តរភាព»។

លោក អ៊ុក រ៉ាប៊ុន បានបន្តទៀតថា ដើម្បីឈានទៅសម្រេចបាននូវគោលដៅនេះ ក្រសួងបាននឹងកំពុងបន្តអនុវត្តនូវផែនការសកម្មភាពជាតិស្តីពីការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទជំហានទី២ ឆ្នាំ២០១៩-២០២៣ ដោយកំណត់យកនូវគោលដៅអត្រាគ្របដណ្តប់ចំនួន ៩០% លើការទទួលបានសេវាទឹកស្អាត និងអនាម័យជនបទនៅឆ្នាំ ២០២៣ ។

ទន្ទឹមនឹងនេះ ក្រសួងក៏បានកំណត់យកខេត្តចំនួន ៥ ឱ្យក្លាយជាខេត្តដែលបញ្ឈប់ការ បន្ទោបង់ពាសវាលពាសកាលនៅឆ្នាំ២០២៣ រួមមាន៖ខេត្តកំពង់ស្ពឺខេត្តកំពង់ឆ្នាំង ខេត្ត កែប ខេត្ត ព្រៃវែង និងខេត្តស្វាយរៀងផងដែរ។

ដើម្បីឈានទៅសម្រេចបាននូវទស្សនវិស័យ ១០០% លោក អ៊ុក រ៉ាប៊ុន ក៏បានអំពាវនាវដល់ដៃគូពាក់ព័ន្ធនានាទាំងអស់ បន្តការចូលរួម និងសហការ សម្រាប់សកម្មភាពលើកកម្ពស់អនាម័យជនបទឲ្យកាន់តែប្រសើរឡើងថែមទៀតតាមរយៈការអនុវត្តនូវ ផែនការសកម្មភាពជាតិស្តីពីការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ៕

# យុវជនជាង២០០នាក់ធ្វើបូជនីយេស៍ រិះគិតពីជំនឿលើព្រះជាម្ចាស់

*អត្ថបទ៖ ដាលីស*



យុវជនមកពីមណ្ឌលសកម្មភាពទាំង៩នៃព្រះសហគមន៍ភូមិភាគភ្នំពេញ ២៣០នាក់ ដឹកនាំដោយលោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ អូលីវីយេ ឆ្មីតហាស្លេ រួមជាមួយក្រុមការិយាល័យយុវជន ជំទង់ កុមារ និងគ្រួសារ ធ្វើបូជនីយេស៍ទៅកាន់ភ្នំវល្លិ៍។ កម្មវិធីនេះធ្វើឡើងនាថ្ងៃទី៤ ដល់៦ កុម្ភៈ ២០២២ ក្រោមប្រធានបទ "ជំនឿធ្វើឱ្យយើងទៅមុខ"។

បូជនីយចរ ចាប់ផ្តើមដោយការអធិដ្ឋានតេហ្សេ និងទទួលការអប់រំពីលោកអភិបាលអូលីវីយេ ៣ដំណាក់កាលក្នុងចម្ងាយផ្លូវ១២គីឡូម៉ែត្រ។

យុវជន ណុប វុទ្ធី មកពីព្រះសហគមន៍ចំការទៀងរៀបរាប់ថា បូជនីយចររយៈចម្ងាយ១២គីឡូនេះ «ជួយខ្ញុំរកឃើញនូវបទពិសោធសប្បាយរីករាយជាខ្លាំង ដោយដឹងពីការធ្វើដំណើរ យល់ពីមិត្តភាពអ្នកនៅជុំវិញខ្លួន រួមទាំងសូត្រធម៌ទៅព្រះជាម្ចាស់ពេលធ្វើដំណើរ»

វុទ្ធីនិយាយថា តាមរយៈការអប់រំរបស់លោកអភិបាលក្នុងបូជនីយចរនេះ «ខ្ញុំដឹងពីវិន័យទាំង១០ប្រការមាន ការមិនសម្លាប់ជីវិត មិនមានចិត្តផិតក្បត់ មិនលួចទ្រព្យគេជាដើម។ បូជនីយចរនេះទោះបីជាមានការនឿយហត់មែន តែមានព្រះជាម្ចាស់ផ្តល់កម្លាំងកាយ កម្លាំងចិត្តដើរទៅមុខទៀត»

រីឯយុវតី វ៉ាន់ សុផារី បច្ចុប្បន្ននៅព្រះសហគមន៍បឹងទំពុន បានឲ្យដឹងថា នេះជាលើកទី៩ហើយដែលនាង បានចូលរួមកម្មវិធីនេះ។ សុផារី បន្តថា «ពេលខ្ញុំដើរ គឺដើរក្នុងអង្គព្រះគ្រីស្ត ដូច្នេះខ្ញុំយល់ថាកាន់តែធ្វើឱ្យជំនឿរបស់ខ្ញុំកាន់តែរឹងមាំ» យុវតីរូបនេះបន្ថែមថា បូជនីចរនេះ ហាក់ដូចជាការផ្សាយដំណឹងល្អមួយដល់អ្នកដែលមិនទាន់ស្គាល់ព្រះសហគមន៍ និងមិនទាន់ស្គាល់ព្រះជាម្ចាស់។ «អ្វីដែលខ្ញុំដើរនៅថ្ងៃនេះ ធ្វើឱ្យខ្ញុំមើលឃើញអ្នកខ្លះដែលកំពុងតែធ្វើចម្ការគេឈប់និងមើលយើងដើរ ធ្វើឱ្យគេដឹងពីការផ្សាយជំនឿយើងនិងពេលដែលខ្ញុំត្រលប់មកវិញ ខ្ញុំអាចបង្រៀនក្មេងកាយឫទ្ធិនិងអប់រំជំនឿដើម្បីបន្តជំនឿបាន»





ក្នុងកម្មវិធីរយៈពេល៣ថ្ងៃនេះ លោកអភិបាលអូលីវីយេ ឆ្មីតហាស្លេ បានបង្រៀនក្រុមយុវជន អំពីចំណុចធំៗគឺ ព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ វិន័យ១០ប្រការ និងកិច្ចការបម្រើនៅក្នុងព្រះសហគមន៍និងសង្គម។

ដំណើរបូជនីយេសក៍នេះបានចាប់ផ្តើមនៅព្រះវិហារសន្តអ្វកូស្ទីណូ ស្ថិតនៅក្នុងឡូមខេត្តកំពត។ មុនចេញដំណើរទៅកាន់ភ្នំវល្លិ៍ លោកអភិបាលអូលីវីយេ បានណែនាំថា យើងជាកីឡាកររបស់ព្រះជាម្ចាស់ យើងដឹងថា ការស្អប់គ្នាត្រូវការដកចេញពីចិត្តរបស់យើង ដោយយើងចង់មានសុភមង្គលដ៏ពិតប្រាកដជាមួយព្រះយេស៊ូ។



លោកបន្តថា ព្រះជាម្ចាស់បានស្រឡាញ់យើង និងចង់ឱ្យយើងមានសុភមង្គល។ ព្រះជាម្ចាស់មានឫទ្ធានុភាព ដើម្បីឲ្យមនុស្សទាំងអស់លិចក្នុងព្រះជាម្ចាស់ជាគ្រួសារតែមួយដ៏ពិតប្រាកដ។ យើងបានមើលឃើញនៅក្នុងឆ្នាំ២០២១ ទោះបីជាមានកូវីដ-១៩ ក៏ដោយ ប៉ុន្តែយើងបានយកចិត្តទុកដាក់ជាគ្រួសារតែមួយ យើងចូលទៅក្នុងការរបស់ព្រះជាម្ចាស់យូរឡើងព្រះជាម្ចាស់ស្រឡាញ់មនុស្សយើង ចង់ឱ្យមនុស្សយើងមានសុភមង្គលមួយដ៏ប្រាកដ។

លោកអភិបាលរំលឹកថា នៅពេលដែលយើងដើរ យើងត្រូវការនឹកឃើញ «តើយើងត្រូវធ្វើដូចម្តេចដើម្បីមានបទពិសោធអំពីព្រះជាម្ចាស់ស្រឡាញ់អាណិត និង ថ្នាក់ថ្នមខ្ញុំ?» និងរកឃើញវត្តមានរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។

នៅដំណាក់កាលទី២ ចូលក្នុងទឹកដីយ៉ូហានប៉ូលទី២សម្រាប់ជីវិត លោកអភិបាលអូលីវី អប់រំអំពីវិន័យ១០ប្រការដែលព្រះជាម្ចាស់បានប្រទានមកឲ្យមនុស្សលោក។ លោកអភិបាលសង្កត់ធ្ងន់ថា «ទោះបីយើងមានសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ តែយើងក៏ត្រូវមានវិន័យផងដែរ» ដើម្បីរស់នៅជាគ្រីស្តបរិស័ទពេញលេញ។ លោកអភិបាលណែនាំទៀតថា ពេលវេលាដែលយើងដើរ យើងចង់ស្វែងរកសុភមង្គលដ៏ពិតប្រាកដ។ នៅពេលនេះ យើងបានរៀនអំពីចំណុច២ គឺសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ និងមានវិន័យ១០ប្រការ។ ហើយចំណុចមួយទៀតដែលមិនអាចខ្វះបាននោះ គឺត្រូវគោរពប្រណិប័តន៍វិន័យទាំង១០ប្រការនេះ។

នៅថ្ងៃបញ្ចប់ លោកអភិបាលព្រះសហគមន៍បានណែនាំឲ្យយុវជនទាំងអស់ ចេះផ្តល់សក្ខីភាពអំពីជំនឿដល់អ្នកដទៃនិងសង្គមជាតិ។ លោកអភិបាលមានប្រសាសន៍ថា «យើងជាគ្រីស្តបរិស័ទត្រូវធ្វើជាសាក្សីអំពីព្រះជាម្ចាស់ សាក្សីនៃសេចក្តីស្រឡាញ់»

លោកអភិបាលអូលីវីយេ បានសង្កត់ធ្ងន់ថា ក្នុងនាមជាយុវជន យើងថ្ងៃនេះទោះបីក្មេងក៏ដោយ ត្រូវធ្វើសាក្សីនៃដំណឹងល្អនិងប្រកាសដំណឹងល្អ ទៅដល់យុវជនផ្សេងៗទៀតដែលគេចង់ស្តាប់។ «យើងមានជីវិតធម្មតា តែយើងបានទទួលពន្លឺ ដោយមានវិន័យនិងជាសាក្សីនៃសេចក្តីស្រឡាញ់ ដើម្បីឱ្យមនុស្សមួយចំនួនធំអាចស្តាប់ដំណឹងល្អអំពីព្រះយេស៊ូដែលគង់នៅ និងរស់នៅជាគ្រួសារតែមួយពីព្រះជាម្ចាស់ផ្ទាល់ និងចូលរួមយ៉ាងសកម្មបំផុត ដើម្បីឲ្យសង្គមទទួលសេចក្តីស្រឡាញ់ យុត្តិធម៌ និងមេត្តាករុណាយ៉ាងជាក់ស្តែងពីព្រះជាម្ចាស់»៕

# រួមគ្នាលើកកម្ពស់វប្បធម៌នៃការយកចិត្តទុកដាក់ និងភាពជាបងប្អូន

*អត្ថបទ៖ កែវ កញ្ញា*



«ការងារនិងទំនាក់ទំនងមានតម្លៃ» នេះជាប្រសាសន៍របស់លោកអភិបាល ទេព ច័ន្ទ ពិសិដ្ឋ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង និងជាប្រធានក្រុមប្រឹក្សាភិបាលនៃអង្គការការីតាសកម្ពុជា នៅក្នុងកម្មវិធីសំណាក់ធម៌នៃអង្គការការីតាសកម្ពុជា ដែលធ្វើឡើងរយៈពេលបីថ្ងៃ ពីថ្ងៃទី១៥-១៨ ខែកុម្ភៈ ឆ្នាំ២០២២ នៅព្រះសហគមន៍តំបន់ភាគខាងលិចក្នុងភូមិភាគបាត់ដំបង។

លោកអភិបាលពិសិដ្ឋ មានប្រសាសន៍ទៅកាន់អង្គប្រជុំទៀតថា "ក្នុងពេលបីថ្ងៃ ឲ្យយើងមានទស្សនៈរស់នៅសាមញ្ញ និងតាមធម្មជាតិ មានទឹកចិត្ត មានបទពិសោធទៅមុខ នាំឲ្យយើងមានអំណរនិងកម្លាំង"។

កម្មវិធីសំណាក់ធម៌របស់អង្គការការីតាសកម្ពុជា បានធ្វើឡើងនៅ២ទីតាំង គឺនៅមណ្ឌលគ្រាប់ (CROAP) ក្នុងខេត្តពោធិ៍សាត់ និងនៅព្រះសហគមន៍តាហែន ក្នុងខេត្តបាត់ដំបង។ កម្មវិធីនេះ រួមបញ្ចូលនូវដំណើរទស្សនកិច្ចផងនិងរិះគិតផងអំពីកិច្ចការងារប្រចាំឆ្នាំរបស់អង្គការក្នុងការបម្រើជនក្រីក្រនៅក្នុងសង្គម ក្រោមប្រធានបទ រួមគ្នាលើកកម្ពស់វប្បធម៌នៃការយកចិត្តទុកដាក់ និងភាពជាបងប្អូន។





ក្នុងធម្មទេសនាបើកកម្មវិធីសំណាក់ធម៌នៅថ្ងៃទី១៥ កុម្ភៈ ទៅកាន់សមាជិកអង្គការការីតាសកម្ពុជាប្រមាណជិត១៥០នាក់ លោកអភិបាលទេព ច័ន្ទ ពិសិដ្ឋ មានប្រសាសន៍ទៀតថា ការងារនិងការទំនាក់ទំនង ទាំងពីរមានតម្លៃ យើងត្រូវបម្រើ ស្តាប់ រិះគិត ស្ងៀមស្ងាត់និងមានសកម្មភាព។

លោបន្តថា ក្នុងសំណាក់ធម៌ប្រចាំឆ្នាំនេះ ឲ្យយើងប្រមូលកម្លាំងស្តាប់ ទាំងការលំបាក និងឧបសគ្គ ហើយយើងក៏មិនភ្លេចការចូលរួម និងធ្វើសកម្មភាពឲ្យបានច្រើន។ ឲ្យមានទំនាក់ទំនងល្អ ចេះស្តាប់ពីបងប្អូន ទាំងការលំបាកនិងបទពិសោធ ដែលពួកគេមាន។

លោកអភិបាលបន្ថែមថា សម្តេចប៉ាបឲ្យយើងចេះស្តាប់គ្នាទៅវិញទៅមក ស្តាប់អ្នកក្រីក្រ និងអ្នកដទៃ ដែលប្រៀបដូចជាព្រះសូរសៀងរបស់ព្រះជាម្ចាស់មានបន្ទូលមកកាន់យើង។ សូមព្រះជាម្ចាស់ប្រទានឲ្យយើងចេះស្តាប់ ចេះអធិដ្ឋាន និងចេះបម្រើបងប្អូន។

នៅថ្ងៃទី២ លោកតូតែត បាណែណាល់ ជាបូជាចារ្យទទួលខុសត្រូវនៅព្រះសហគមន៍សៀមរាប បានណែនាំអំពីរចនាសម្ពន្ធរបស់ព្រះសហគមន៍កាតូលិក មានតាំងពីសម្តេចប៉ាប រហូតដល់លោកអភិបាល និងបូជាចារ្យនៅក្នុងប្រទេសនានា និងរចនាសម្ពន្ធរបស់ព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជាផងដែរ។

លោកបូជាចារ្យតូតែត បានសង្កត់ធ្ងន់ថា អង្គការការីតាស ជាអង្គការមួយរបស់ព្រះសហគមន៍កាតូលិក ដែលធ្វើការងារក្នុងកិច្ចការសង្គហៈរបស់ព្រះសហគមន៍។ លោកបានបញ្ជាក់ថា «នៅក្នុងព្រះសហគមន៍មានបីក្រុមធំៗ គឺមាន ពិធីបុណ្យ អប់រំជំនឿ និងសង្គហៈ ហើយអង្គការការីតាសគឺស្ថិតនៅក្នុងសង្គហៈ ដែលជួយដល់អ្នកក្រីក្រ អ្នកខ្វះខាតនៅក្នុងសង្គម»

លោកបូជាចារ្យពន្យល់ទៀតថា ដូច្នេះហើយការងាររបស់ការីតាសកម្ពុជាគឺជាអង្គការរបស់ព្រះសហគមន៍ ស្ថិតក្រោមការដឹកនាំរបស់លោកអភិបាល និងធ្វើការនៅក្នុងសង្គម ដើម្បីសម្តែងសេចក្តីមេត្តាករុណារបស់ព្រះយេស៊ូ ដោយគ្មានប្រកាន់អ្នកណាឡើយ។

លោកបានបញ្ជាក់ទៀថា គោលដៅរបស់ព្រះសហគមន៍កាតូលិក គឺប្រកាសជំនឿ និងសម្តែងធម៌មេត្តាករុណា ដែលជាសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ឲ្យគ្នាទៅវិញទៅមក។

ដើម្បីឲ្យសមាជិកនៃអង្គការការីតាសកម្ពុជា ដែលភាគច្រើនជាពុទ្ធបរិស័ទបានយល់ដឹងបន្ថែមអំពីទិសដៅរបស់ព្រះសហគមន៍នៅក្នុងសង្គមបច្ចុប្បន្ន លោកអភិបាលអូលីវីយេ ឆ្មីតហស្លេ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបានមានប្រសាសន៍ថា «យើង(អង្គការការីតាស) មិនត្រឹមតែមានឯកទេសជាន់ខ្ពស់ តែត្រូវមានសេចក្តីស្រឡាញ់ ចិត្តមេត្តាករុណា និងទំនាក់ទំនង ដើម្បីបង្កើតពិភពមួយមានយុត្តិធម៌ និងសុខសន្តិភាព ឲ្យអ្នកក្រមានតម្លៃ»

លោកអភិបាលក៏បានជំរុញឲ្យបុគ្គលិកនៃអង្គការនេះ យកពេលវេលាដើម្បីស្តាប់ និងសួរសុខទុក្ខអ្នកក្រីក្រដោយផ្ទាល់ ដែលជាកម្លាំងណែនាំឲ្យគេយល់ថា គេមិនឯកោហើយមានកំលាំងចិត្តធ្វើកិច្ចការរបស់គេ។ លោកអភិបាលបានសង្កត់ធ្ងន់ថា «យើងត្រូវដូរ(របៀប)ទំនាក់ទំនង និងឥរិយាបទ ដើម្បីរួមគ្នាលើកកម្ពស់វប្បធម៌នៃការយកចិត្តទុកដាក់ និងភាពជាបងប្អូន»

ក្នុងការណែនាំរយៈពេលជាងមួយម៉ោងនៅថ្ងៃទី២នេះ លោកអភិបាលអូលីវីយេ ពន្យល់ទៀតថា កិច្ចការងារសំខាន់គឺការបម្រើត្រូវចូលក្នុងចិត្ត ចូលក្នុងផ្លូវវិញ្ញាណរបស់យើង ដើម្បីប្រែជីវិតរស់នៅរបស់យើងផ្ទាល់ខ្លួន និងអ្នកដទៃដែរ។

ក្នុងនោះដែរ លោកអភិបាលបានរំលឹកអំពីជំងឺកូវីដ-១៩ ដែលបានរំខានជីវិតនិងទំនាក់ទំនងក្នុងការរស់នៅរបស់ប្រជាជននាពេលសព្វថ្ងៃនេះ។ លោកបានបញ្ជាក់ថា មនុស្សយើងចង់បានកាន់តែច្រើនទៅៗ គិតអំពីសម្ភារនិយម ប៉ុន្តែកូវីដបង្រៀនយើងឲ្យគិតរបៀបថ្មី គឺការរស់នៅសាមញ្ញ ការសិក្សា សុខភាព ម្ហូបអាហារ ទំនាក់ទំនងរវាងគ្នានិងគ្នា។

លោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ បានជំរុញឲ្យអ្នកចូលរួមទាំងអស់ ត្រូវចេះថែរក្សាអំណរសប្បាយនិងសេចក្តីសុខសាន្ត ដោយរស់នៅកសាងក្រុមគ្រួសារល្អ កូនបានទទួលការសិក្សាសុខភាពល្អ មិនមែនដោយសារតែមានលុយច្រើននោះឡើយ។ ជាមួយគ្នានេះ លោកអភិបាលក៏សង្កត់ធ្ងន់ថា «គ្រប់វិស័យដែលយើងធ្វើការគឺហ្នឹងឲ្យគេរីកចម្រើនក្នុងអំណរនិងសេចក្តីសុខសាន្ត»

លោកបានបញ្ជាក់ទៀតថា «រស់នៅក្នុងសង្គមត្រូវចេះស្រឡាញ់និងបម្រើក្នុងសង្គម ដើម្បីសង្គមរីកចម្រើន។ កុំឲ្យយើងក្លាយជាពលរដ្ឋអាត្មានិយម តែគឺណែនាំឲ្យយើងចេះកសាងសង្គមរីកចម្រើន»៕





# បេក្ខជន ចំនួន១៥ នាក់ សុំចូលព្រះសហគមន៍





*អត្ថបទ៖ កែវ កញ្ញា*

ក្នុងសំលៀកបំពាក់អាវស និងសំពត់ឬខោពណ៌ខ្មៅឬខៀវ ឈរតម្រង់ជាពីរជួរនៅមុខព្រះវិហារសន្តសិលានិងសន្តប៉ូលដែលមានទ្វារបិទជិត បេក្ខជនពេញវ័យចំនួន១៥នាក់បាន គោះទ្វារព្រះវិហារ។ លោកបូជាចារ្យសិលា សួន ហង្សលី បូជាចារ្យទទួលខុសត្រូវព្រះវិហារ និងជាប្រធានមណ្ឌលសកម្មភាពភ្នំពេញថ្មី បានស្រែកសួរពីចម្ងាយថា «តើអ្នកមករកអ្វី?» បេក្ខជនទាំងអស់បានឆ្លើយព្រមគ្នាថា «ខ្ញុំមកសុំចូលព្រះសហគមន៍»។

លោកបូជាចារ្យបានស្វាគមន៍ពួកគេ ដោយបើកទ្វារឲ្យចូលក្នុងព្រះវិហាររួមជាមួយគ្រីស្តបរិស័ទនានា។

នេះជាកម្មវិធីមួយដែលព្រះសហគមន៍កាតូលិកនៅកម្ពុជាបានធ្វើឡើង សម្រាប់អស់អ្នកមកឈ្វេងយល់ជំនឿ ដែលជាដំណាក់កាលដំបូងមុនពេលទទួលអគ្គសញ្ញាជ្រមុជទឹក គឺជាពិធីសុំចូលព្រះសហគមន៍ឬហៅថា ជំហានទី១ ។

កម្មវិធីនេះបានធ្វើឡើងនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២២ នៅព្រះវិហារសន្តសិលានិងសន្តប៉ូល ស្ថិតនៅក្នុងភូមិក្រាំងអង្ក្រង សង្កាត់ក្រាំងធ្នង់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

លោក សោម លោកា អាយុ៣៦ឆ្នាំ បានឲ្យដឹងថា គាត់ស្គាល់ព្រះសហគមន៍តាមរយៈបងប្អូនរបស់គាត់ និងតាមរយៈការងារដែលគាត់កំពុងធ្វើសព្វថ្ងៃនេះដែលជាបុគ្គលិកបម្រើការងារផ្នែកទទួលស្វាគមន៍ភ្ញៀវរបស់មណ្ឌលសកម្មភាពភ្នំពេញថ្មី។

លោក លោកា បានបញ្ជាក់ថា ៖ «ខ្ញុំបានចូលរួមញឹកញាប់ជាមួយសកម្មភាពរបស់ព្រះសហគមន៍ ជាពិសេសគឺកម្មវិធីសប្បុរសធម៌។ ខ្ញុំសប្បាយចិត្ត និងរំភើបមែនទែន ទោះបីខ្ញុំជួយបានត្រឹមតែកម្លាំង ប៉ុន្តែខ្ញុំមានអារម្មណ៍រំភើបនៅពេលឃើញព្រះសហគមន៍មានទឹកចិត្ត សប្បុរសធម៌សម្រាប់បងប្អូនរបស់យើង»។

ដោយសារចំណុចនេះ បានជំរុញឲ្យលោក សោម លោកា សម្រេចចិត្តរៀនអប់រំជំនឿ ដោយមានការគាំទ្រពីក្រុមគ្រួសាររបស់គាត់ផងដែរ។

រីឯ យុវតី វ៉ន ចំប៉ា កំពុងបម្រើការងារនៅក្នុងសាលាដុនបូស្កូទឹកថ្លា ជាបេក្ខជនម្នាក់ទៀតបានឲ្យដឹងថា នាងបានសិក្សាឈ្វេងយល់អំពីជំនឿរបស់ព្រះសហគមន៍កាតូលិកជិតមួយឆ្នាំមកហើយ។

កញ្ញា ចំប៉ា បាននិយាយថា ការផ្លាស់ប្តូរជំនឿរបស់គាត់ពីពុទ្ធបរិស័ទមកគ្រីស្តបរិស័ទនេះ មិនងាយស្រួលនោះទេ ដោយសារក្រុមគ្រួសារជាពុទ្ធបរិស័ទទាំងអស់ ហើយឪពុកម្តាយក៏មិនសូវពេញចិត្តនឹងជំនឿថ្មីរបស់គាត់ដែរ។

យុវតីរូបនេះថា ៖ «ខ្ញុំនឹងបង្ហាញពួកគាត់ ទោះបីជាខ្ញុំជាគ្រីស្តបរិស័ទ ប៉ុន្តែគ្រីស្តបរិស័ទក៏ជាមនុស្សល្អនៅក្នុងសង្គម ចេះជួយសង្គម និងចេះគោរពឪពុកម្តាយ ចេះធ្វើអំពើល្អជាច្រើនសម្រាប់គ្រួសារនិងសង្គម និងខ្លួនឯងដែរ»។

ក្នុងកម្មវិធីសុំចូលព្រះសហគមន៍នេះ លោកបូជាចារ្យ សិលា សួន ហង្សលី បានឲ្យបេក្ខជនទាំង១៥រូប ឈរនៅមុខអាសនៈ នៅមុខគ្រីស្តបរិស័ទចាស់ក្មេងទាំងអស់ រួចសួរបញ្ជាក់ឲ្យបេក្ខជនទាំងអស់លះបង់ពិធីផ្សេងៗដែលមានដូចជា ពិធីសែនព្រេន ពិធីបញ្ជាន់អារក្សអ្នកតាដែលមិនណែនាំឲ្យគោរពបម្រើព្រះជាម្ចាស់។ គ្រប់គ្នាបានឆ្លើយថា «យើងខ្ញុំសម្រេចចិត្តហើយ»

បន្ទាប់មកពួកគាត់ទាំងអស់បានលុតជង្គង់នៅមុខព្រះឈើឆ្កាង និងព្រះគម្ពីរ ដោយសុំយកអង្គទាំងពីរជាទីពឹង និងបែរមករកព្រះសហគមន៍ដែលមានគ្រីស្តបរិស័ទជាច្រើន ហើយសុំយកព្រះសហគមន៍ជាទីពឹងផងដែរ។

ជាមួយគ្នានោះ លោកបូជាចារ្យអធិបតី បានធ្វើសញ្ញាឈើឆ្កាងនៅលើថ្ងាស លើវិញ្ញាណទាំង៥ និងលើខ្លួនរបស់បេក្ខជន។

គូសញ្ញាឈើឆ្កាងលើខ្លួនបងប្អូន ដើម្បីឲ្យបងប្អូនក្លាយទៅជាអ្នកទទួលការអប់រំជំនឿ។ គូសលើត្រចៀកដើម្បីឲ្យបងប្អូនអាចស្តាប់លឺព្រះបន្ទូល គូសលើភ្នែក ដើម្បីឲ្យអាចមើលឃើញពន្លឺរបស់ព្រះជាម្ចាស់ គូសលើមាត់ គឺដើម្បីឲ្យចេះឆ្លើយនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ គូសលើទ្រូង គឺដើម្បីឲ្យព្រះគ្រីស្តគង់នៅក្នុងបងប្អូនដោយសារជំនឿ និងគូសលើស្មា គឺដើម្បីឲ្យបងប្អូនពាក់នឹមរបស់ព្រះគ្រីស្តដោយចិត្តរីករាយ។

បេក្ខជនដែលបានទទួលពិធីសុំចូលព្រះសហគមន៍ នឹងត្រូវរៀននិងត្រៀមខ្លួនបន្ថែមទៀតមុនទទួលអគ្គសញ្ញាជ្រមុជទឹក៕

# ព្រះវិហារសន្តយ៉ូសែបនិងជួងព្រះនាងម៉ារី ពោធិ៍បាន ត្រូវបានសម្ពោធជាផ្លូវការណ៍ហើយ





*អត្ថបទ៖ ដាលីស*

សំឡេងចម្រៀងលើកតម្កើងព្រះជាម្ចាស់បានលាន់ឮឡើង ដោយមានមនុស្សជាច្រើនដើរប្រទក្សិណបីជុំនៅជុំវិញព្រះវិហារថ្មីមួយ ដែលមានបណ្តោយ២២ម៉ែត្រ និងទទឹង៩ម៉ែត្រ នោះគឺព្រះវិហារសន្តយ៉ូសែបនៃព្រះសហគមន៍ពោធិ៍បាន ដែលស្ថិតនៅក្នុងមណ្ឌលសកម្មភាពទន្លេបាសាក់។

«វិហារនេះមិនមែនជាកន្លែងធម្មតា តែជាព្រះដំណាក់ព្រះជាម្ចាស់។» នេះជាការថ្លែងពីលោកអភិបាល អូលីវីយេ ផ្មិតហាស្លេ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ក្នុងពិធីសម្ពោធព្រះវិហារសន្តយ៉ូសែប និងជើងជួងព្រះនាងម៉ារី នៅព្រះសហគមន៍ពោធិ៍បាន ក្នុងខេត្តកណ្តាល។

លោកអភិបាលមានប្រសាសន៍ថា ៖ «ពិធីឆ្លងព្រះវិហារថ្មី យើងបានដើរ៣ជុំដើម្បីយល់ថាជាកន្លែងមួយពិសេស ជាកន្លែងសក្ការៈ ចេញពីជីវិតលោកីយ៍ចូលមកកន្លែងសក្ការៈ ជាកន្លែងដែលមានវត្តមានព្រះជាម្ចាស់»។

ព្រះវិហារនេះ ត្រូវបានសាងសង់ឡើង កាលពីថ្ងៃ២២ ខែកក្កដា ឆ្នាំ២០២០ និងបញ្ចប់នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១។ ព្រះវិហារថ្មីនេះកសាងឡើងដោយមានការចូលរួមសហការពីសំណាក់គ្រីស្តបរិស័ទដោយរែអង្គាសថវិកាគ្នាទាំងក្នុងនិងក្រៅប្រទេស។

ព្រះវិហារថ្មីនេះ មានឈ្មោះជាផ្លូវការថា «ព្រះវិហារសន្តយ៉ូសែប» រីឯជើងជួងដែលមានកម្ពស់១៨ម៉ែត្រ ត្រូវបានដាក់ឈ្មោះថា «ជើងជួងព្រះនាងម៉ារី» ស្ថិតនៅក្នុង ស្រុកកោះធំ ខេត្តកណ្តាល ដែលត្រូវដាក់សម្ពោធជាផ្លូវការនាថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២២កន្លងទៅនេះ។

ព្រះវិហារសន្តយ៉ូសែបនៃព្រះសហគមន៍ពោធិ៍បាន មានលោកបូជាចារ្យសិលា ឡេវ៉ាន់ទីន ជាអ្នកទទួលខុសត្រូវ។ លោកមានប្រសាសន៍ថា ៖ «ថ្ងៃនេះជាថ្ងៃរីករាយនិងសំខាន់បំផុតនៅព្រះសហគមន៍ពោធិ៍បាន យើងចាប់ផ្តើមធ្វើក្នុងសម័យកូវីដ១៩ ដោយគ្មានសង្ឃឹមថានឹងអាចបញ្ចប់ការកសាងបានទេ។ ប៉ុន្តែទោះជាយ៉ាងណាក្តី ព្រះជាម្ចាស់បានបង្ហើយកិច្ចការងារនេះ»។

ក្នុងពិធីនោះ លោកអភិបាលអូលីវីយេ បានប្រោះទឹកព្រះពរលើគ្រីស្តបរិស័ទ ដើម្បីរំឭកដល់អគ្គសញ្ញាជ្រមុជទឹក ដោយទឹកនាំឱ្យគ្រីស្តបរិស័ទទទួលជីវិតថ្មីរួមជាមួយព្រះយេស៊ូគ្រីស្ត និងប្រោះទឹកលើជញ្ជាំងព្រះវិហារ ព្រមទាំងលើអាសនៈ ជាសញ្ញាលាងជម្រះឱ្យស្អាតបរិសុទ្ធក្លាយជាព្រះដំណាក់របស់ព្រះជាម្ចាស់។ *បន្តទៅទំព័រ-១៩*

# លោក អូលីវីយេ ៖ «អគ្គសញ្ញាលាបថ្វាស ផ្តល់កម្លាំងទៅប្រកាសដំណឹងល្អ»





*អត្ថបទ៖ ដាលីស*

គ្រីស្តបរិស័ទកាតូលិកនៃព្រះសហគមន៍មណ្ឌលសកម្មភាពទន្លេមេគង្គ ចំនួន ៤១ រូបទទួលអគ្គសញ្ញាលាបថ្វាស ដែលជាការទទួលព្រះវិញ្ញាណដ៏វិសុទ្ធតាមជំនឿរបស់ព្រះសហគមន៍កាតូលិក ដើម្បីក្លាយទៅជាគ្រីស្តបរិស័ទពេញវ័យខាងជំនឿ។

ពិធីនេះធ្វើឡើង ក្រោមអធិបតីភាពលោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ អូលីវីយេ ឆ្មីតហាស្លេរ នៅព្រះវិហារព្រះនាងម៉ារីមិនជំពាក់បាប (សំរោងធំ) ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២២។

បេក្ខនារី ណៃ ប៊ុននី ជាគ្រីស្តបរិស័ទនៅព្រះសហគមន៍សំរោងធំបាននិយាយថា អគ្គសញ្ញាលាបថ្វាសនៅថ្ងៃនេះធ្វើឱ្យនាងរំភើប ព្រះវិញ្ញាណដ៏វិសុទ្ធជួយឱ្យនាងសប្បាយរីករាយ។

បេក្ខជន ង៉ៀង វីងវិន ឲ្យដឹងថាដែរថា អគ្គសញ្ញានេះជួយឱ្យគាត់មានកម្លាំង មានអំណរសប្បាយខ្លាំង និងបានជួបលោកអភិបាល។

វីងវិន បានប្រាប់ថា ៖ «ក្រោយពីទទួលអគ្គសញ្ញាលាបថ្វាសនេះ ខ្ញុំចង់បម្រើព្រះជាម្ចាស់ដោយ ប្រើទេពកោសល្យរបស់ខ្ញុំ។ ខ្ញុំនឹងចូលរួមជាមួយក្រុមចម្រៀង ព្រោះខ្ញុំស្រឡាញ់ខ្លាំង»។

បេក្ខជនទាំងនេះមកពី ព្រះសហគមន៍រោងចក្រ, ព្រះសហគមន៍ព្រែកដាច់, ព្រះសហគមន៍សំរោងធំ និងព្រះសហគមន៍កំពង់ចម្លង។

សញ្ញាលាបថ្វាសគឺជាអគ្គសញ្ញាដ៏សំខាន់មួយនៅក្នុងព្រះសហគមន៍កាតូលិក ក្នុងចំណោមអគ្គសញ្ញាទាំង៧ មានដូចជាអគ្គសញ្ញាជ្រមុជទឹកអគ្គសញ្ញាសម្រុះសម្រួល អគ្គសញ្ញាទទួលព្រះកាយនិងព្រះលោហិតព្រះគ្រីស្ត អគ្គសញ្ញាអាពាហ៍ពិពាហ៍ អគ្គសញ្ញាតែងតាំងជាបូជាចារ្យ និងអគ្គសញ្ញាលាបប្រេងផ្តល់កម្លាំង។

«អគ្គសញ្ញាលាបថ្វាសគឺព្រះវិញ្ញាណដ៏វិសុទ្ធដែលមានសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ជាជីវិតផ្ទាល់របស់ព្រះជាម្ចាស់ ជាព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ផ្ទាល់ ជាសេចក្តីក្លាហាននិងកម្លាំងរបស់ព្រះជាម្ចាស់ផ្ទាល់ដែលនឹងសណ្ឋិតលើបងប្អូនដើម្បីទៅជាសាក្សីរបស់ព្រះជាម្ចាស់»។ នេះជាថ្លែងឡើងរបស់លោកអភិបាលអូលីវីយេ ឆ្មីតហាស្លេរ។

លោកអភិបាលបានបញ្ជាក់ថា ៖ «កុំឱ្យយើងស្រឡាញ់តែបបូរមាត់ ប៉ុន្តែសូមឱ្យយើងចេះស្រឡាញ់ដោយជាក់ស្តែងនៅក្នុងសកម្មភាពរបស់យើងដែលមានពីមួយថ្ងៃទៅមួយថ្ងៃ»៕

# ក្រុមសហជីវិនព្រះយេស៊ូមានប្រធានដឹកនាំថ្មី

*អត្ថបទសម្រួលពីhttps://jcapsj.org*

លោកឪពុក អាធួ៌ សូសា (Fr. Arturo Sosa, SJ) ប្រធានក្រុមគ្រួសារបព្វជិតសហជីវិនព្រះយេស៊ូពិភពលោក បានតែងតាំងលោកឪពុក វ៉ុន អូឆាង ស៊ីម៉ូន (Fr Kwon Oh-chang Simon, SJ) ជាប្រធានក្រុមគ្រួសារបព្វជិតសហជីវិនព្រះយេស៊ូ (Jesuit) នៅកម្ពុជា។ លោកឪពុកវ៉ុន នឹងចូលកាន់តំណែងបន្តពីលោកពុក អូ អ៊ីនដុន ហ្វ្រាន់ស៊ីស្កូ (Fr Oh In-don Francisco, SJ) ដែលបានបម្រើការតាំងពីឆ្នាំ ២០១៣ ។

លោកឪពុកវ៉ុន កើតនៅឆ្នាំ ១៩៦៨ នៅទីក្រុងអង់ដុង (Andong) ប្រទេសកូរ៉េខាងត្បូង។ លោកបានចូលក្នុងក្រុមបព្វជិត សហជីវិនព្រះយេស៊ូ នៅថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ២០០៣ បន្ទាប់ពីបានបញ្ចប់ការសិក្សាពីសាលាច្បាប់នៅសាកលវិទ្យាល័យជាតិសេអ៊ូល។ លោកពុកវ៉ុន បានតែងតាំងជាបូជាចារ្យនៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ ហើយបានថ្វាយសច្ចានិរន្តរ៍ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ ។

លោកបានមកដល់ប្រទេសកម្ពុជាជាលើកដំបូងក្នុងឆ្នាំ២០០៨ ដោយបម្រើការងារនៅ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងផ្ទះសម្រាប់ជនមានពិការភាព បន្ទាយព្រាប ក្នុងខេត្តកណ្តាល។ បន្ទាប់មក លោកបានចាកចេញពីប្រទេសកម្ពុជាទៅបន្តការសិក្សាផ្នែកទេវវិទ្យា នៅទីក្រុងប៊ើខេឡៃ (Berkeley) ក្នុងរដ្ឋកាលីហ្វ័រញ៉ា (California) នៃសហរដ្ឋអាមេរិក ហើយបន្ទាប់មកបានត្រឡប់ទៅស្រុកកំណើត ហើយបានតែងតាំងជាបូជាចារ្យក្នុងប្រទេសកូរ៉េខាងត្បូង។



*លោកបូជាចារ្យ អូ អ៊ីនដុន (ឆ្វេងដៃ) លោកបូជាចារ្យ អូ ឆាង (ស្តាំ)។*

បន្ទាប់ពីការតែងតាំង លោកឪពុកវ៉ុន បានបម្រើការជាជំនួយការបូជាចារ្យព្រះសហគមន៍កាតូលិក អ៊ូកស៊ូ ហើយបន្ទាប់មក ក្លាយជានាយកខាងវិញ្ញាណនៅមជ្ឈមណ្ឌលសំណាក់ធម៌របស់ក្រុមសហជីវិនព្រះយេស៊ូ (Jesuit retreat center) នៅសាន់ជុន (Suncheon) ។ គាត់ត្រូវបានចាត់ឲ្យមកប្រទេសកម្ពុជាវិញមួយឆ្នាំក្រោយមក ក្នុងមុខងារជាអ្នកទទួលខុសត្រូវ សហគមន៍នៅព្រាបស (Prieb So Jesuit) ក្នុងទីក្រុងភ្នំពេញ ខណៈពេលដែលគាត់កំពុងសិក្សាភាសាខ្មែរឲ្យកាន់តែស៊ីជម្រៅ។

គាត់ត្រូវបានចាត់តាំងជានាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ជនមានពិការភាព បន្ទាយព្រាបពីឆ្នាំ ២០១៥ រហូតដល់ឆ្នាំ ២០១៨ ហើយត្រូវចាត់ឲ្យទៅ Girisonta, Semarang ប្រទេសឥណ្ឌូនេស៊ីសម្រាប់ Tertianship ។ ចាប់តាំងពីលោកត្រឡប់មកប្រទេសកម្ពុជាវិញ លោកបានបំពេញការងារជានាយកសម្រាប់ការត្រាស់ហៅ ខណៈនោះ លោកក៏បានណែនាំក្រុមយុវជននៃព្រះវិហារសន្តហ្វ្រង់ស្វ័រ សាវីយេ (St Francis Xavier Parish) ក្នុងក្រុងសិរីសោភ័ណ ក្នុងភូមិភាគបាត់ដំបង។ លោកឪពុក វ៉ុន ក៏ជាហិរញ្ញិករបស់ក្រុមគ្រួសារសហជីវិនព្រះយេស៊ូ និងជាប្រធានគណៈកម្មាធិការខាងផ្លូវវិញ្ញាណផងដែរ។ លោកផ្តល់ការណែនាំខាងវិញ្ញាណសម្រាប់សមាជិកទាំងអស់នៃក្រុមគ្រួសារអ្នកបួសនេះ។

សមាជិកសហជីវិនព្រះយេស៊ូនិងអ្នកពាក់ព័ន្ធនានា នៅកម្ពុជា ក៏ដូចជានៅក្នុងព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង មានសេចក្តីរីករាយជាខ្លាំង អំពីដំណឹងនៃការតែងតាំងលោកពុក វ៉ុន អូឆាង ស៊ីម៉ូន ជាតំណាងក្រុមគ្រួសារនៃតំបន់កូរ៉េសម្រាប់បេសកកម្មក្រុមសហជីវិនព្រះយេស៊ូនៅកម្ពុជា។ សរសេរក្នុងនាមក្រុមសហជីវិនព្រះយេស៊ូ និងដៃគូបេសកកម្ម លោកឪពុកអូ អ៊ីនដុន បានសម្តែងការអបអរសាទរ និងដឹងគុណចំពោះលោកឪពុកវ៉ុន ហើយបានផ្តល់ការគាំទ្រយ៉ាងពេញទំហឹងដល់គាត់ ខណៈដែលគាត់ទទួលយកបេសកកម្មបម្រើប្រជាជនកម្ពុជា។

សន្និសីទសហជីវិនព្រះយេស៊ូនៃប្រធានអាស៊ីប៉ាស៊ីហ្វិក លោកឪពុកតូនី ម៉ូរេណូ (Fr Tony Moreno, SJ) ក៏ស្វាគមន៍ការដឹកនាំរបស់លោកឪពុកវ៉ុន នៅក្នុងសន្និសីទនេះដែរ។ ដោយលោកមានប្រសាសន៍ថា «បេសកកម្មនៅកម្ពុជាកំពុងប្រឈមមុខនឹងបញ្ហាប្រឈមដ៏ធំធេង ហើយយើងក៏ត្រូវបានសម្រាលទុក្ខដោយការរីកចម្រើនបន្តិចម្តងៗនៃយុវជន វ័យក្មេង និងកិច្ចការបម្រើទាំងមូល»។ លោកក៏បានថ្លែងអំណរគុណដល់លោកឪពុក អូ អ៊ីនដុន «សម្រាប់រយៈពេលប្រាំបួនឆ្នាំនៃការបម្រើ និងការដឹកនាំប្រកបដោយការយកចិត្តទុកដាក់របស់គាត់នៅក្នុងបេសកកម្មនៅកម្ពុជា និងនៅក្នុងសន្និសីទរបស់យើង»។

លោកឪពុក វ៉ុន អូឆាង ស៊ីម៉ូន នឹងចូលកាន់តំណែងជាតំណាងក្រុមគ្រួសារនៃតំបន់កូរ៉េសម្រាប់បេសកកម្មក្រុមសហជីវិនព្រះយេស៊ូនៅកម្ពុជានៅថ្ងៃទី ១ ខែមេសា ឆ្នាំ២០២២នេះ៕

# ដូនជីបីរូបនៃក្រុមគ្រួសារឧបការគុណប្រកាសពាក្យសច្ចានិរន្តរ៍

*អត្ថបទ៖ កែវ កញ្ញា*

ក្នុងសំលៀកបំពាក់អាវស និងសំពត់បត់ខ្មៅ ដូនជីឧបការគុណចំនួន៣រូប លុតជង្គង់នៅមុខអាសនៈនៃព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន ដើម្បីសុំការប្រទានពរពីព្រះជាម្ចាស់ និងប្រកាសពាក្យសច្ចានិរន្តរ៍របស់ខ្លួននៅ មុខព្រះសហគមន៍និងក្រុមគ្រួសារអ្នកបួសក្រុមដូនជីឧបការគុណនៅព័រស៊ី។

«សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ធំជាងអំពើបាបរបស់ខ្ញុំ ធំជាងចំណុចទន់ខ្សោយរបស់ខ្ញុំធ្វើឲ្យខ្ញុំមានចិត្តក្លាហាន ហ៊ានឆ្លើយតបទៅនឹងព្រះជាម្ចាស់ដោយថ្វាយពាក្យសច្ចានិរន្តរ៍អស់មួយជីវិតជាមួយក្រុមគ្រួសារបងស្រីឧបការគុណនៅព័រស៊ីប្រទេសកម្ពុជា»។ នេះជាសម្តីរបស់ដូនជីអាញ៉ែសពែរប៉េទុយអា រ៉ុង បុប្ផាដែលជាបេក្ខនារី ថ្វាយពាក្យសច្ចាប្រណិធាននិរន្តរ៍។

ដូនជីអាញ៉ែសពែរប៉េទុយអា រ៉ុង បុប្ផា ជាកូនពៅក្នុងចំណោមគ្រួសារជាគ្រីស្តបរិស័ទ។ ដូនជីរូបនេះសច្ចាលើកដំបូងនៅថ្ងៃទី ១៥ ខែសីហា ២០១៤។ ដូនជីរូបនេះឲ្យដឹងថា គាត់ស្រឡាញ់ជីវិតជាអ្នកបួសខ្លាំង ដោយសារគំរូរបស់បងស្រីជាច្រើនបានជម្រុញឲ្យចិត្តរបស់គាត់ដែលជាកូនពៅមានកម្លាំងទៅមុខ។

បងស្រីឲ្យដឹងថា៖ «ខ្ញុំអធិដ្ឋានប្រាប់ព្រះជាម្ចាស់ថា ខ្ញុំមិនអាចទៅមុខបានទេ ដោយសារខ្ញុំសិក្សាទៅឃើញថា ជីវិតរបស់ខ្ញុំមិនអាចមាននរណាត្រួតត្រាខ្ញុំបាន។ ខ្ញុំមានចំណេះដឹងរបស់ខ្ញុំ ហេតុអ្វីខ្ញុំត្រូវស្តាប់គេ?»

បងស្រីបុប្ផាបានបញ្ជាក់ថា ដោយសារសេចក្តីស្រឡាញ់ជីវិតជាអ្នកបួស និងការគាំទ្រពីក្រុមគ្រួសារផ្ទាល់ និងក្រុមគ្រួសារអ្នកបួស រួមផ្សំនិងការអធិដ្ឋានយ៉ាងខ្លាំងជារៀងរាល់ថ្ងៃ បានធ្វើឲ្យបងស្រីដាក់ខ្លួនទទួលការស្តាប់បង្គាប់ពីប្រធានក្រុមគ្រួសារ។

បច្ចុប្បន្ន ដូនជីរ៉ុង បុប្ផា កំពុងបម្រើការងារនៅព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង ក្នុងមុខងារជាអ្នកមើលការខុសត្រូវមណ្ឌលចំនួន២របស់ក្រុមគ្រួសារឧបការគុណនៅបាត់ដំបង មើលការខុសត្រូវលើសាលាមត្តេយ្យក្នុងព្រះសហគមន៍នៅពេទ្យឃាយជី(ខេត្តបាត់ដំបង) និងសាលាមត្តេយ្យរបស់បងស្រីឧបការគុណនៅកំពង់ឆ្នាំង។ គាត់ក៏មានមុខងារមួយទៀតគឺជាបុគ្គលិករបស់អង្គការជេស្វិតសឺវីសកម្ពុជា។

ក្នុងពិធីថ្វាយពាក្យសច្ចាប្រណិធាននិរន្តរ៍នេះមានដូនជីបីរូប រួមមាន បងស្រី ហ្វ្លស្ទីណាម៉ារី បៀ នារី, បងស្រី ម៉ារីណាតាលី ថាត់ ធារី និងបងស្រីអាញ៉ែសពែរប៉េទុយអា រ៉ុង បុប្ផា។

កម្មវិធីនេះ បានប្រារព្ធឡើង ក្រោមអធិបតីភាពអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ លោកអូលីវីយេ ផ្មិតហាស្លេ, អភិបាលព្រះសហគមន៍ភូមិភាគបាត់ដំបង លោក អេនរីគេ ហ្វីការេដូ និងអភិបាលចូលនិវត្តន៍ លោកអន់តូនី សាមីស៊ូសែរាជ្យ នៃព្រះសហគមន៍ភូមិភាគកំពង់ចាម។

ពិធីសច្ចាប្រណិធានដ៏ឱឡារិកនេះប្រព្រឹត្តទៅនៅព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន នាថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២២ ត្រូវនឹងថ្ងៃរំឭកខួប២៦០ឆ្នាំនៃការបង្កើតក្រុមគ្រួសារឧបការគុណ (១៧៦២-២០២២) និង១៤១ឆ្នាំដែលក្រុមគ្រួសារនេះមានវត្តមាននៅកម្ពុជា។

លោកអភិបាលអូលីវីយេ បានថ្លែងឡើងថា ថ្ងៃនេះបងស្រីបានធ្វើពាក្យសច្ចាសារជាថ្មី សុខចិត្តរស់នៅជាអ្នកក្រខ្សត់ សុខចិត្តលះបង់ចោលដោយរស់នៅព្រហ្មចារីយ៍ និងស្តាប់បង្គាប់ គឺដើម្បីនឹកឃើញដល់ពេលវេលារបស់អ្នកបួសទាំងអស់ដែលផ្ញើជីវិតទាំងស្រុង និងជាពិសេសដើម្បីឲ្យយុវជនយុវនារីភ្ញាក់ស្មារតីសម្រាប់ការត្រាស់ហៅ។

លោកមានប្រសាសន៍ថា ៖ «ពេលវេលានេះសម្រាប់យុវនារីដើម្បីទទួលពន្លឺរបស់ព្រះយេស៊ូដែលនាំឲ្យជីវិតរបស់យើងជាជីវិតពោរពេញដោយអំណរសប្បាយយ៉ាងពិសេសដែលមកពីព្រះជាម្ចាស់»។

ជាពេលវេលាសម្រាប់ព្រះសហគមន៍នីមួយៗនៅក្នុងភូមិភាគភ្នំពេញ បាត់ដំបង និងកំពង់ចាម បន្តអធិដ្ឋានសម្រាប់ការត្រាស់ហៅនិងបន្តជាសក្ខីភាពជាគ្រួសារមួយយ៉ាងពិសេស ដែលនាំឲ្យយុវជនយុវនារីរកឃើញគ្រួសារមួយយ៉ាងកក់ក្តៅដោយមើលឃើញពន្លឺរបស់ព្រះគ្រីស្ត គឺដើម្បីឲ្យព្រះគ្រីស្តមានវត្តមានថែមទៀតនៅលើទឹកដី កម្ពុជា។

លោកថ្លែងថា ៖ «យើងមានពេលច្រើនដើម្បីទុកឲ្យព្រះអាទិត្យនៃព្រះជាម្ចាស់ព្រះនៅក្នុងដួងចិត្តរបស់យើងដើម្បីឱ្យយើងកក់ក្តៅ ដោយសារទទួលពន្លឺរស្មីត្រចះត្រចង់មកពីព្រះហឫទ័យសន្តោសរបស់ព្រះជាម្ចាស់ពិតមែន»។

ដូនជី ហ្វ្លស្ទីណាម៉ារី បៀ នារី បានឱ្យដឹងថា គាត់បានឮការត្រាស់ហៅរប់ព្រះជាម្ចាស់នៅអាយុ១៤ឆ្នាំ ប៉ុន្តែដោយសារតែម្តាយជាពុទ្ធបរិស័ទមិនអនុញ្ញាតដូនជីរូបនេះបានរង់ចាំរហូតដល់ពេលវេលាមួយ។

ដូនជីបៀ នារី ថា៖ «ពេលនោះខ្ញុំអធិដ្ឋានជាមួយព្រះជាម្ចាស់ប្រសិនបើព្រះអង្គសព្វព្រះហឫទ័យសូមព្រះអង្គកែប្រែចិត្តគំនិតរបស់ម្តាយខ្ញុំ និងក្រោយមកគ្រួសារខ្ញុំមានបញ្ហាច្រើនខ្ញុំបានសម្រេចចិត្តមិនទៅបួស»។

ចំណែក ដូនជី ម៉ារីណាតាលី ថាត់ ធារី បានឱ្យដឹងពីបទពិសោធក្នុងជីវិតអ្នកបួសថា ៖ «ការអធិដ្ឋានជាកម្លាំងរបស់ខ្ញុំផ្ទាល់ និងការរស់នៅជីវិតជាក្រុមធ្វើឲ្យខ្ញុំមានអំណរសប្បាយផង និងទុក្ខលំបាកផងដោយយើងរស់នៅជាមួយគ្នាជាជីវិតអ្នកបួសដែលខុសពីក្រុមគ្រួសារ ដោយយើងរៀនរស់នៅជាមួយគ្នារៀនស្រឡាញ់គ្នា»។

បច្ចុប្បន្នបងស្រីកំពុងបម្រើការងារនៅក្នុងព្រះសហគមន៍កាតូលិកក្នុងភូមិភាគភ្នំពេញផ្នែកអប់រំជំនឿ បង្រៀនភ្លេងដល់កុមារអូទីហ្សឹម កុមារនិងក្រុមដូនជី ព្រមទាំងបង្រៀនភាសាបារាំងផងដែរ។

ដូនជីធារី ឲ្យដឹងថា៖ «ខ្ញុំទៅមុខដោយជឿជាក់ថាព្រះអង្គរួមដំណើរជាមួយខ្ញុំ ហើយខ្ញុំនឹងមានសុភមង្គល និងមិនស្តាយក្រោយ ដោយសប្បាយជានិច្ចនូវជម្រើសរបស់ខ្ញុំ ហើយបណ្តោយខ្លួនតាមការណែនាំរបស់ព្រះឧបការគុណតែម្តង»។

ក្នុងនោះដែរ បងស្រី បុប្ផាជម្រុញឲ្យយុវជនទាំងអស់រិះគិតអំពីការត្រាស់ហៅរបស់ព្រះជាម្ចាស់ចំពោះខ្លួន ជាពិសេសគឺជាអ្នកបួស។

ក្រោយពេលសង្គ្រាមស៊ីវិល ព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជាបានបាត់បង់អ្វីស្ទើរតែទាំងស្រុង រួមមានលោកអភិបាលជាតិខ្មែរ យ៉ូសែប ឆ្មារសាឡាស់ និងសហការី លោកអភិបាលទេព អ៊ឹម សុថា រួមនឹងក្រុមបព្វជិត-ជិតា និងគ្រីស្តបរិស័ទជាច្រើនទៀត។ ហេដ្ឋារចនាសម្ពន្ធរបស់ព្រះសហគមន៍ត្រូវគេបំផ្លាញស្ទើរទាំងស្រុងផងដែរ៕









# បុគ្គលិកភូមិភាគកំពង់ចាម រួមគ្នាធ្វើកម្មវិធីសំណាក់ធម៌ និងដំណើរកំសាន្ត លើទឹកដីអង្គរ ខេត្តសៀមរាប

*អត្ថបទដោយ៖ ហៀម សុកខុន*

«យើងជាមហាគ្រួសារតែមួយ រួមដំណើរជាមួយគ្នាដោយក្តីស្រឡាញ់» គឺជាប្រធានបទនៃកម្មវិធីសំណាក់ធម៌និងដំណើរកំសាន្ត ដែលបានធ្វើឡើងកាលពីថ្ងៃទី២៤ដល់ទី២៧ ខែកុម្ភៈ ឆ្នាំ២០២២កន្លងទៅនេះ ក្រោមវត្តមានរបស់លោកអភិបាល ប្រ៊ុយ ណូ កូសម៍ និងបុគ្គលិកភូមិភាគកំពង់ចាមចូលរួមសរុបប្រមាណជា៧០នាក់។

លោក ហេង រ៉ាវី ប្រធានបុគ្គលិកភូមិភាគកំពង់ចាម បានបង្ហាញពីគោលបំណងនៃកម្មវិធីនេះថា ព្រះសហគមន៍ភូមិភាគធ្វើកម្មវិធីនេះឡើងដើម្បីលើកទឹកចិត្តបុគ្គលិក បង្កើនភាពស្និតស្នាលរវាងបុគ្គលិកនិងបុគ្គលិក ជាពេលវេលាមួយសម្រាប់បន្ថែមកម្លាំងចិត្ត និងមានគោលដៅសម្រាប់ការងារ និងជីវិតផ្ទាល់ខ្លួនម្នាក់ៗផងដែរ។

លោក ហេង រ៉ាវី បន្តថា ៖ «នេះជាលើកទីមួយដែលមានបងប្អូនជាបុគ្គលិកព្រះសហគមន៍មកពី៣២ព្រះសហគមន៍ដែលបានធ្វើកម្មវិធីសំណាក់ធម៌និងធ្វើដំណើរកំសាន្តរួមគ្នានេះ ដែលក្នុងនោះមាន៨តំបន់ រួមទាំងការិយាល័យកណ្តាលនៃភូមិភាគកំពង់ចាមផងដែរ»។

បុគ្គលិកព្រះសហគមន៍ទូទាំងភូមិភាគកំពង់ចាមមានចំនួន១១៤នាក់ ប៉ុន្តែពួកគាត់មិនបានចូលរួមទាំងអស់គ្នានោះទេដោយសារតែអ្នកខ្លះមានបញ្ហាសុខភាព អ្នកខ្លះមានការរវល់ផ្ទាល់ខ្លួនជាដើម។



*រូបភាពដោយ ស៊ីអេសស៊ីកំពង់ចាម*

ប្រធានមណ្ឌលកអ្វាំងឌី លោក ហាក់ គឹម សាន បានឲ្យដឹងដែរថា លោកពិតជាចាប់អារម្មណ៍ខ្លាំងដោយសារតែលោកបានឃើញបុគ្គលិកជាច្រើនរបស់ព្រះសហគមន៍មិនថាចាស់ឬយុវជន បានរិះគិតក៏ដូចជាពិភាក្សាជាមួយគ្នាអំពីលក្ខណៈឬលក្ខខណ្ឌដែលបានធ្វើការងារឲ្យព្រះសហគមន៍កន្លងមក។

លោកថា ៖ «ពេលមកដល់ទីតាំងសំណាក់ធម៌មានអារម្មណ៍ថា ទទួលបានអារម្មណ៍កក់ក្តៅ មានអំណរសប្បាយ មានកំលាំងចិត្តកាន់តែខ្លាំង ព្រោះថាមានលោកអភិបាល លោកពុក បងស្រី និងបងប្អូនជាបុគ្គលិកព្រះសហគមន៍ នៅជាមួយគ្រប់ពេលទាំងការអធិដ្ឋាន ទាំងអភិបូជា ទាំងការញ៉ាំ ការដើរលេង និងកម្មវិធីសប្បាយៗជាច្រើនទៀត»។

ចំណែកលោកស្រី ញឹក ស្រីវ៉ាន់ ដែលជាប្រធានផ្នែកអប់រំកុមារតូចក្នុងភូមិភាគកំពង់ចាមនិងសព្វថ្ងៃជាគ្រូមត្តេយ្យនៅព្រះសហគមន៍ចម្លាក់ ក៏បានមានប្រសាសន៍ដែរថា លោកស្រីពិតជាចាប់រម្មណ៍ខ្លាំងណាស់ទាក់ទងនឹងប្រធានបទ ដែលជាមហាគ្រួសារតែមួយ រួមដំណើរជាមួយគ្នាដោយក្តីស្រលាញ់។

លោកស្រីបន្តថា ក្នុងឱកាសដែលបានទៅសំណាក់ធម៌ក៏ដូចជាដំណើរកំសាន្តជុំគ្នានេះ ធ្វើឲ្យលោកស្រី និងបុគ្គលិកទាំងអស់មានបទពិសោធន៍ចំពោះគ្នាទៅវិញទៅមក ជាពិសេសបានចែករំលែកបទពិសោធន៍ការងារតាមព្រះសហគមន៍នីមួយៗ ធ្វើឲ្យស្គាល់បងប្អូនដែលមិនធ្លាប់បានស្គាល់ពីមុនមក និងធ្វើឲ្យរូបលោកស្រីនិងបងប្អូនផ្សេងៗក្នុងព្រះសហគមន៍មានទំនាក់ទំនង ជាមួយគ្នាយ៉ាងជិតស្និត។

កញ្ញា ឌី សុខលី ពីព្រះសហគមន៍ក្តុលលើបានប្រាប់ឲ្យដឹងដែរថា ក្នុងរយៈពេលប៉ុន្មានថ្ងៃក្នុងកម្មវិធីសំណាក់ធម៌ ក៏ដូចជាដំណើរកំសាន្តពិតជាល្អសម្រាប់កញ្ញា ព្រោះថាការងារក្នុងព្រះសហគមន៍គឺត្រូវបម្រើព្រមទាំងមានការលះបង់។

កញ្ញា ឌី សុខលី បានបន្តថា ក្នុងកម្មវិធីសំណាក់ធម៌នេះកញ្ញាស្គាល់បុគ្គលិកមកពីព្រះសហគមន៍ផ្សេងៗ មានពេលអធិដ្ឋានជាមួយគ្នា យល់កាន់តែច្បាស់ពីរបៀបធ្វើការនៅក្នុងព្រះសហគមន៍ របៀបក្នុងការដោះស្រាយតាមតួនាទីនីមួយៗ អ្វីដែល

# គ្លីនិកកូមីសូ បង្កើតឡើង ដើម្បីជួយអ្នកក្រីក្រដែលគ្មាន លទ្ធភាពព្យាបាលជំងឺ





*អត្ថបទ៖ ដាលីស*

គ្លីនិកកូមីសូ (KOMISO CLINIC) ដែលកសាងដោយអង្គការសមាគមសាសនទូតកូរ៉េ ក្នុងភូមិត្រពាំងសាលា សង្កាត់ពងទឹក ខណ្ឌដង្កោរ រាជធានីភ្នំពេញ ត្រូវបានប្រទានពរតាមជំនឿនៃព្រះសហគមន៍កាតូលិក និងសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការណ៍ នាថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២២កន្លងទៅនេះ។

ពិធីនេះត្រូវបានប្រារព្ធឡើង ក្រោមអធិបតីភាពលោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ អូលីវីយេ ជ្មីតហាស្លេរ ដោយមានវត្តមានលោកបូជាចារ្យ និងតំណាងគ្រីស្តបរិស័ទមួយចំនួនផងដែរ។

លោកបូជាចារ្យ ជី ហ៊ុន ដែលទទួលខុសត្រូវគ្លីនិកកូមីសូនេះ បានថ្លែងថា គ្លីនិកនេះកសាងឡើងក្នុងគោលបំណងជួយអ្នកក្រីក្រដែលគ្មានលទ្ធភាពព្យាបាល ហើយលោកសង្ឃឹមថាគ្លីនិកនេះជាឧបករណ៍របស់ព្រះជាម្ចាស់នៅក្នុងកិច្ចការបម្រើអ្នកក្រីក្រ។

លោកបូជាចារ្យ ជី ហ៊ុន មានប្រសាសន៍អំពីដើមហេតុនៃការបង្កើតឱ្យមានគ្លីនិកនេះថា ពីមុនក្រុមកូរ៉េធ្លាប់មកជួយផ្នែកសុខភាពនិងមានទំនាក់ទំនងជាមួយនឹងប្រជាជននៅទីនេះ និងមានគម្រោងការផ្ញើសិស្សស្ម័គ្រចិត្តកូរ៉េផ្នែកថ្នាំពេទ្យដែលមានបទពិសោធនៅកម្ពុជា ក៏ប៉ុន្តែដោយសារតែមេរោគកូវីដ១៩ ទើបពួកគេមិនអាចមកបាន។

លោកថា ៖ «ដោយហេតុនេះ ទើបយើងបង្កើតឱ្យមានគ្លីនិកដោយចាប់ផ្តើមពីការជួលបន្ទប់តូច និងចាប់ពីឆ្នាំ២០២០មកយើងចាប់ផ្តើមកសាងអាគារធំដើម្បីងាយស្រួលជួយដល់អ្នកជំងឺ»។

ថ្លែងនៅក្នុងធម្មទេសនានៃពិធីបុណ្យអភិបូជាប្រទានពរគ្លីនិកនេះ លោកអភិបាលអូលីវីយេ មានប្រសាសន៍រំឭកថាព្រះយេស៊ូទៅកន្លែងណាតែងតែមានប្រជាជននិងអ្នកជំងឺគ្រប់ប្រភេទទៅកន្លែងនោះ ហើយកន្លែងនេះនឹងធ្វើឱ្យគ្រប់គ្នានឹកឃើញដល់ព្រះយេស៊ូ។

លោកអភិបាលបានថ្លែងថា៖«យើងត្រូវព្យាបាលទាំងរូបកាយ និងផ្លូវវិញ្ញាណ។ សង្ឃឹមថាគ្លីនិកនេះមិនមែនជាកន្លែងមួយដែលត្រឹមតែរូបកាយទេ ក៏ប៉ុន្តែជាកន្លែងមួយដែលយល់ច្បាស់លាស់អំពីតម្រូវការរបស់អ្នកជំងឺ និងយល់ពីស្ថានភាពពួកគាត់ ដើម្បីជួយគាត់ឱ្យមានសេចក្តីសុខសារជាថ្មី»។

លោកក៏បានរំឭកទៀតថា សម្តេចប៉ាបបានអញ្ជើញឲ្យចូលរួមក្នុងមហាសន្និបាតក្រោមប្រធានបទ «ដើរជាមួយគ្នា» និងធ្វើដំណើរជាមួយគ្នានៅក្នុងព្រះសហគមន៍ភូមិភាគភ្នំពេញ ដោយរួមគ្នាប្រកាសដំណឹងល្អតាមរយៈគ្រប់វិស័យទាំងអស់ក្នុងនាមព្រះយេស៊ូដែលចាត់ឲ្យទៅប្រកាសដំណឹងល្អ។ ហេតុនេះហើយកន្លែងនេះជាកន្លែងដែលត្រូវប្រកាសដំណឹងល្អក្នុងនាមជាគ្រីស្តបរិស័ទ។

លោកអភិបាល អូលីវីយេ បានបន្តថា ៖ «ជាឱកាសមួយដើម្បីឱ្យយើងគិតសារជាថ្មីតាមរយៈកម្មវិធីផ្សេងៗដើម្បីទៅជាសាក្សីរបស់ព្រះជាម្ចាស់ដោយណែនាំឱ្យអ្នកតូចតាចជាពិសេសអ្នកដែលគ្មានទីពឹងអាចរកឃើញពន្លឺថ្មី និងអាចធ្វើដំណើរទៅមុខបាន»។

លោកបានបន្តទៀតថា ៖ «នេះជាពេលវេលាមួយដើម្បីឱ្យយើងគិតសារជាថ្មីដើម្បីកសាងព្រះសហគមន៍នៅលើទឹកដីកម្ពុជា។ ភូមិភាគភ្នំពេញរបស់យើងគឺប្លែក ដែលមានសាសនទូតក្រៅប្រទេសច្រើននិងមិនសូវមានបូជាចារ្យ បងស្រី កើតចេញពីកម្ពុជាផ្ទាល់»។

អភិបាលរូបនេះបានបញ្ជាក់ថា គោលដៅទីមួយ គឺធ្វើយ៉ាងណាឱ្យអ្នកទាំងអស់គ្នាមានអារម្មណ៍កក់ក្តៅដែលធ្វើដំណើររួមជាមួយគ្នាដោយចែករំលែកបទពិសោធន៍រួមជាមួយគ្នា និងមានកន្លែងដើម្បីចែករំលែក។

លោកថា៖«វិស័យសុខភាពអាចទៅមុខលុះត្រាតែយើងរួមគ្នានៅក្នុងការសហការ នៅក្នុងការយល់ដឹងក្នុងនាមបព្វជិតបព្វជីតាដែលមានព្រះយេស៊ូជាពន្លឺបំភ្លឺយើងដើម្បីណែនាំបងប្អូនឲ្យទៅជាពលរដ្ឋល្អមានសុខភាពល្អ មានសេចក្តីសង្ឃឹម និងមានកម្លាំងកាយកម្លាំងចិត្ត ដើម្បីប្រកាសដំណឹងល្អលើទឹកដីកម្ពុជា»។

ក្រោយអភិបូជា លោកអភិបាលបានប្រសិទ្ធិពរលើទឹកដែលរំឭកអំពីអគ្គសញ្ញាជ្រមុជទឹកដែលជាជីវិតថ្មី និងប្រោសទឹកព្រះពរលើមនុស្សនិងអាគារគ្លីនិក រួចកាត់ខ្សែបូណ៍ដែលជាសញ្ញាបង្ហាញថាដាក់ឱ្យប្រើប្រាស់ជាផ្លូវការណ៍។

តាមការឱ្យដឹងពីលោក អៀ ទីទី (Ea Titi) ប្រធានផ្នែកកម្មវិធីសុខភាពកូមីសូ បានលើកឡើងថា គ្លីនិកនេះមានអាគារផ្នែកធ្មេញ ដោយបំពាក់នូវឧបករណ៍ចំនួន៥ និងម៉ាស៊ីនថតx-ray បន្ទប់សម្អាតធ្មេញ បន្ទប់ពិគ្រោះ បន្ទប់សម្អាតសម្ភារ។

លោកបន្តថា ផ្នែកជំងឺទូទៅមាន៦បន្ទប់ ក្នុងនោះមាន បន្ទប់ក្រុមហ៊ុនកូមីសូដើម្បីគ្រប់គ្រងដីគ្លីនិក បន្ទប់អ្នកជំងឺសម្រាករយៈពេលខ្លី បន្ទប់ការិយាល័យ បន្ទប់វះកាត់តូច បន្ទប់សម្អាតសម្ភារៈ បន្ទប់ថ្នាំពេទ្យ បន្ទប់ថតនិងតេស្តឈាម និងឃ្លាំង។

គ្លីនិកកូមីសូ នឹងចាប់ផ្តើមទទួលអ្នកជំងឺឱ្យមកទទួលសេវាកម្មព្យាបាលនៅបុណ្យចូលឆ្នាំខ្មែរខាងមុខនេះ៕

# សំណាក់ធម៌ចែករំលែកបទពិសោធន៍នៃការអប់រំជំនឿ

*អត្ថបទ៖ ហៀម សុកខុន*

ព្រះសហគមន៍ភូមិភាគកំពង់ចាមរៀបចំកម្មវិធីសំណាក់ធម៌គ្រូអប់រំជំនឿ លើប្រធានបទបទពិសោធនៃការប្រណិប័តន៍ជំនឿ ដែលមានអ្នកចូលរួមចំនួន៣១នាក់ ណែនាំដោយលោកបូជាចារ្យ អាល់ប៊ែរតូ កាការ៉ូ ចាប់ពីថ្ងៃទី១០-១២ ខែកុម្ភៈ ឆ្នាំ២០២២ នៅព្រះសហគមន៍សន្តហ្វ្រង់ស្វ័រ និងសន្តីក្លារា អាស៊ីស៊ី ស្ថិតនៅក្នុងភូមិកោះរកាក្រៅ ឃុំកោះរការ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

ដូនជី តេរេសា ចាន់ វឌ្ឍា ជាអ្នកសម្របសម្រួលកម្មវិធីបានឲ្យដឹងថា ព្រះសហគមន៍រៀបចំកម្មវិធីសំណាក់ធម៌នេះឡើង ដើម្បីប្រមូលគ្រូអប់រំជំនឿនៅក្នុងព្រះសហគមន៍ឡើងវិញ ដើម្បីឲ្យពួកគាត់អធិដ្ឋានរួមគ្នា សួរសុខទុក្ខគ្នា បង្កើនទំនាក់ទំនងជាមួយគ្នា រិះគិតអំពីព្រះបន្ទូលជាមួយគ្នា និងរិះគិតពីជីវិតរស់នៅប្រចាំថ្ងៃជាមួយគ្នា។



ដូនជី វឌ្ឍា បន្តថា ដោយសារតែវិបត្តិកូវីដ-១៩ ចូលមកក្នុងប្រទេសកម្ពុជាយើងអស់រយៈពេលយ៉ាងយូរ ទើបធ្វើឲ្យគ្រូអប់រំជំនឿតាមព្រះសហគមន៍នីមួយៗ ក្នុងភូមិភាគកំពង់ចាមអាក់ខានជួបគ្នាក្នុងកម្មវិធីផ្សេងៗ។

កញ្ញា ឃឹម សុខា ជាសាមណេរីក្នុងក្រុមគ្រួសារស្រឡាញ់ឈើឆ្កាងព្រះយេស៊ូ និងជាគ្រូអប់រំជំនឿមកពីព្រះសហគមន៍កំពង់ចាមក្រុង បានឲ្យដឹងដែរថា នៅគ្រប់កាលៈទេសៈ នៅគ្រប់ទីកន្លែង ទោះបីរវល់នឹងការងារក៏ដោយ ក៏អាចប្រកាសអំពីជំនឿរបស់ព្រះជាម្ចាស់ទៅកាន់អ្នកដទៃបានដែរ មិនថាពេលសប្បាយឬពេលកើតទុក្ខ គឺជួបព្រះជាម្ចាស់។

សាមណេរីរូបនេះ បញ្ជាក់ថា ៖ «ដើម្បីបន្តជំនឿទៅកាន់អ្នកដទៃបាន លុះត្រាតែគ្រូអប់រំជំនឿមានជំនឿរឹងមាំខ្លួនឯងសិន ស្គាល់អំពីព្រះគម្ពីរ និងព្រះសហគមន៍ឲ្យបានច្បាស់លាស់ ត្រូវចេះរៀបមេរៀនឲ្យបានត្រឹមត្រូវ និងមានដំណាក់កាលដើម្បីបង្រៀនគេកាន់តែងាយស្រួលនឹងឆាប់យល់ និងត្រូវមានសៀវភៅមេរៀនទៅតាមដំណាក់កាលរបស់អ្នកមកទទួលអប់រំ ដោយយកព្រះគម្ពីរជាទីពឹង»។

ចំណែក លោក ប៉ូល ផលមើយ ជាគ្រូអប់រំជំនឿមកព្រះសហកមន៍អ្នកលឿង បាននិយាយថា កម្មវិធីសំណាក់ធម៌លើកនេះពិតជាល្អខ្លាំងណាស់សម្រាប់លោក មានឱកាសសំណាក់ធម៌រយៈពេលមួយថ្ងៃពេញ ព្រមទាំងបានចែករំលែកបទពិសោធឲ្យគ្នាទៅវិញទៅមកក្នុងជីវិតជាគ្រីស្តបរិស័ទ ទាំងអ្នកចាស់និងអ្នកថ្មី និងបានសួរសុខទុក្ខគ្នាទៅវិញទៅមក និងបានជួយពង្រឹងជំនឿបន្ថែម។

លោកគ្រូអប់រំជំនឿរូបនេះ បន្ថែមថា ៖ «ខ្ញុំសុំឲ្យព្រះសហគមន៍ធ្វើកម្មវិធីអធិដ្ឋានតេហ្សេ និងកម្មវិធីផ្សេងៗឲ្យបានច្រើនដើម្បីឲ្យគ្រីស្តបរិស័ទអាចចូលរួមអធិដ្ឋានជាមួយគ្នា និងមានទំនាក់ទំនងល្អជាមួយគ្នា និងជាមួយព្រះជាម្ចាស់»។

រីឯង អ្នកស្រី ហួត ហ៊ាង ជាគ្រូអប់រំជំនឿមកពីព្រះសហគមន៍កោះរការក្រៅ ក៏បានប្រាប់ដែរថា រយៈពេល២ថ្ងៃនៃការសំណាក់ធម៌ ធ្វើឲ្យអ្នកស្រីយល់មួយកំរិតទៀត ពីរបៀបនៃការអប់រំឬបន្តជំនឿទៅកាន់អ្នកដទៃ។

អ្នកស្រី ហួត ហ៊ាង ថ្លែងថា ៖ «ខ្ញុំអរព្រះគុណព្រះជាម្ចាស់ ដែលបានញែកពេលវេលាដើម្បីឲ្យខ្ញុំមកក្នុងកម្មវិធីសំណាក់ធម៌នេះ ធ្វើឲ្យខ្ញុំមានកំលាំងកាន់តែខ្លាំងមកពីព្រះជាម្ចាស់»។

ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាមគ្របដណ្តប់លើខេត្តចំនួន៨ ដូចជា កំពង់ចាម ព្រៃវែង ស្វាយរៀង ត្បូងឃ្មុំ ក្រចេះ ស្ទឹងត្រែង រតនគិរី និងខេត្តមណ្ឌលគិរី៕

# សន្និសីទអំពីការត្រាស់ហៅជីវិតជាបូជាចារ្យនៅទីក្រុងរ៉ូម

*អត្ថបទ៖ កែវ កញ្ញា*

«ត្រូវជិតស្និទ្ធហើយជិតស្និទ្ធទៀតជាមួយព្រះជាម្ចាស់» ជាសារមួយសម្រាប់អស់បូជាចារ្យ និងលោកអភិបាលដែលសម្តេចប៉ាបហ្វ្រង់ស៊ីស្កូមានបន្ទូលនៅក្នុងសន្និសីទស្តីអំពីការត្រាស់ហៅជីវិតជាបូជាចារ្យកាតូលិក។ នេះបើតាមសម្តីរបស់លោកបូជាចារ្យផាន បូរី ដែលបានចូលរួមក្នុងកម្មវិធីនេះ កាលពីថ្ងៃទី១៧-១៩ ខែកុម្ភៈ ឆ្នាំ២០២២នៅទីក្រុងរ៉ូម។





លោកបូជាចារ្យផាន បូរីមានប្រសាសន៍ឲ្យដឹងថា សន្និសីទនេះ គឺធ្វើឡើងដើម្បីឲ្យបូជាចារ្យយល់ដឹងបន្ថែមអំពីរបៀបថែទាំជីវិតផ្លូវវិញ្ញាណរក្សាជីវិតជាបូជាចារ្យ និងលើកទឹកចិត្តបូជាចារ្យឲ្យខិតខំប្រកាសដំណឹងល្អតាមរបៀបថ្មី។

ក្នុងកម្មវិធីនេះ មានតំណាងពីប្រទេសកម្ពុជាចំនួនបីរូប គឺលោកបូជាចារ្យផាន បូរី លោកបូជាចារ្យសែ សាត និងលោកបូជាចារ្យ អេទៀន។

លោកបូជាចារ្យបូរី ឲ្យដឹងទៀតថា សម្តេចប៉ាបមានបន្ទូលថា ជាបូជាចារ្យត្រូវរស់នៅជិតស្និទ្ធជាមួយព្រះជាម្ចាស់ តាមរយៈការអធិដ្ឋាន និងថ្វាយអភិបូជា។ បន្ទាប់មកត្រូវចេញទៅធ្វើកិច្ចការងារមេត្តាករុណានៅក្នុងសង្គម។ ជាបូជាចារ្យត្រូវមានតួនាទីជាគង្វាល ដោយរស់នៅជិតស្និទ្ធជាមួយបងប្អូន គឺត្រូវចេញពីបន្ទប់របស់ខ្លួន ទៅរកបងប្អូន ដើម្បីដឹងអំពីតម្រូវការរបស់ពួកគេ។

លោកបូជាចារ្យបន្ថែមថា ក្នុងកម្មវិធីនេះ សម្តេចប៉ាបក៏សង្កត់ធ្ងន់ដែរថា គំរូរបស់លោកបូជាចារ្យ គឺមានសារៈសំខាន់ណាស់សម្រាប់យុវ៉ន ឲ្យពួកគេបានឃើញអំពីការត្រាស់ហៅជាជីវិតជាបូជាចារ្យសប្បាយរីករាយ ឲ្យពួកគេចង់ធ្វើជាបូជាចារ្យ។

ក្នុងនោះដែរ សម្តេចប៉ាបរំលឹកថា លោកបូជាចារ្យត្រូវមានទំនាក់ទំនងជាមួយលោកអភិបាល ទទួលយកអ្វីដែលជាចំណុចវិជ្ជមាន ហើយលោកអភិបាលត្រូវរស់នៅជាឪពុករបស់លោកបូជាចារ្យ។

សន្និសីទនេះជាកម្មវិធីអប់រំម្យ៉ាង ដែលទីក្រុងរ៉ូមបានអញ្ជើញលោកបូជាចារ្យ លោកអភិ បាល និងបងស្រី(ចំនួនតិចតួច) មកពីគ្រប់ប្រទេសមកចូលរួម។ លោកបូរី បន្តថា ៖ «សម្តេចប៉ាបមានបន្ទូលទៀតថា សម័យបច្ចុប្បន្នលោកបូជាចារ្យមានការល្បួងច្រើនដូចជា ស្រា ស្រី អំណាច ទ្រព្យសម្បត្តិជាដើម។ ចំណុចទាំងនេះ ជួយខ្ញុំឲ្យពិចារណាឡើងវិញអំពីជីវិតជាបូជាចារ្យរបស់ខ្ញុំផងដែរ»។

លោកបូជាចារ្យផាន បូរី ជាបូជាចារ្យខ្មែរមួយរូបក្នុងចំណោមលោកបូជាចារ្យជាតិខ្មែរចំនួន ៨នាក់ ដែលបានទទួលអគ្គសញ្ញាតែងតាំងក្នុងឆ្នាំ ២០១៤។ ប្រទេសកម្ពុជា ជាប្រទេសមួយដែលមានគ្រីស្តបរិស័ទកាតូលិកតិចតួច គឺប្រមាណ ២ម៉ឺននាក់ ដែលជាប្រទេសស្ថិតនៅក្នុងប្រទេសដែលត្រូវបំពេញបេសកកម្មនៃការប្រកាសដំណឹងល្អរបស់ព្រះជាម្ចាស់។

លោកបូជាចារ្យបូរី ៖ «សន្និសីទនេះ ជួយដាក់សតិសម្បជញ្ញៈរបស់ខ្ញុំក្នុងជីវិតជាបូជាចារ្យ។ ពេលខ្លះ យើងភ្លេចខ្លួន ធ្វើតែធម៌មេត្តាករុណា ភ្លេចកិច្ចការស្នូលរបស់យើង គឺអធិដ្ឋាននិងអភិបូជា នាំឲ្យយើងចាកចេញពីជីវិតបូជាចារ្យយ៉ាងងាយស្រួល។ ពេលយើងរស់នៅឯកោ យើងងាយធ្លាក់ក្នុងការល្បួង ដូច្នេះត្រូវរស់នៅជាក្រុមគ្រួសារ»។

លោកបញ្ជាក់ទៀតថា ក្នុងរយៈពេលបីថ្ងៃនៃពិធីជួបជុំនេះ នាំឲ្យលោកអាចរកឃើញភាពរឹង ភាពរឹងមាំក្នុងជីវិតជាបូជាចារ្យ គឺ «រស់នៅដោយបន្ទាបខ្លួន ដោយបម្រើដោយគ្មានអួតខ្លួន»។

លោកបូជាចារ្យសែ សាត បានឱ្យដឹងដែរថា សន្និសីទនេះបានដាស់តឿនឲ្យលោករិះរករបៀបថែទាំ និងបញ្ជូនបន្តជំនឿដល់គ្រីស្តបរិស័ទក្នុងតំបន់របស់លោកដែលកំពុងទទួលខុសត្រូវ ដែលជាកន្លែងថ្មីគ្រីស្តបរិស័ទជំនាន់ថ្មីផងដែរ។

លោកបូជាចារ្យបានឲ្យដឹងថា កន្លងមកព្រះសហគមន៍បានធ្វើសកម្មភាពជាច្រើនដើម្បីប្រកាសដំណឹងល្អ តាមរយៈការសួរសុខទុក្ខចាស់ជរា ជនក្រីក្រតាមផ្ទះ អធិដ្ឋានតាមផ្ទះ ផ្តល់អាហារនិងសម្ភារមួយចំនួនដល់អ្នកខ្វះខាត សង់ផ្ទះដល់ជនក្រីក្រជាដើម។

លោកបូជាចារ្យសាតបន្ថែមថា ការលើកទឹកចិត្តដល់គណៈកម្មការចំនួន៣ក្រុមក្នុងព្រះសហគមន៍ពិតជាមានសារៈសំខាន់ដើម្បីជួយដល់កិច្ចការប្រកាសដំណឹងល្អក្នុងព្រះសហគមន៍ ដែលមានគណៈកម្មការពិធីបុណ្យ គណៈកម្មការសង្គហៈ និងគណៈកម្មការអប់រំជំនឿជាដើម។

លោកសាតបន្ថែមថា លោកនឹងរកឱកាសដើម្បីផ្សាយបន្តនូវគំនិតរបស់សន្និសីទនេះក្នុងសិក្ខាសាលា ឬធម្មទេសនាផ្ទាល់របស់លោក។

ក្នុងឱកាសនោះ លោកបូជាចារ្យទាំងបីរូបក៏បានជួបសម្តែងការគួរសមជាមួយសម្តេចប៉ាបហ្វ្រង់ស៊ីស្កូដោយផ្ទាល់ ហើយបានថ្វាយនូវក្រមាខ្មែរដែលមានប៉ាក់រូបអង្គរវត្ត។ សម្តេចប៉ាបបានប្រទានពរដល់លោកទាំងបីផងដែរ៕

# លោកបូជាចារ្យ បុង បុង ប្រកាសពាក្យសច្ចានិរន្តរ៍

*អត្ថបទ៖ កក ស្រីនិ*

«ពេលខ្ញុំដាក់ពាក្យពីជាង២០ឆ្នាំមុន ក្នុងក្រុមគ្រួសារជេស្វីតពីមុននៅហ្វីលីពីន ខ្ញុំស្មានថាគេអត់ទទួលខ្ញុំ ដោយសារខ្ញុំគិតថា គេទទួលតែមនុស្សដែលឆ្លាតៗតែប៉ុណ្ណោះ មនុស្សដែលសង្ហា។» នេះជាប្រសាសន៍របស់លោកបូជាចារ្យ ចន ឡេស្ទើរ៍ តាហូន (បុង បុង) តំណាង ពេញសិទ្ធិលោកអភិបាលព្រះសហគមន៍កាតូលិកក្នុងភូមភាគបាត់ដំបង ក្នុងពិធីថ្វាយពាក្យសច្ចានិរន្តរ៍របស់លោកកាលពីពេលថ្មីនេះ។



លោកបូជាចារ្យបុង បុង ជាជនជាតិហ្វីលីពីន ត្រូវបានតែងតាំងជាបូជាចារ្យកាតូលិកនៅក្នុងថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៣។ បីខែក្រោយមកលោកត្រូវបានចាត់ឲ្យមកបម្រើការងារនៅក្នុងប្រទេសកម្ពុជា។

លោកបូជាចារ្យដែលមានវ័យ ៤៨ឆ្នាំរូបនេះ បាននិយាយដោយរអ្សួលដើមក និងសម្រក់ទឹកភ្នែក ក្នុងពិធីថ្វាយពាក្យសច្ចាចុងក្រោយរបស់លោក ដោយនឹករលឹកដល់ម្តាយរបស់លោក ដែលកំពុងតាមដានពិធីថ្វាយពាក្យសច្ចានិរន្តរ៍របស់គាត់ពីចម្ងាយ តាមប្រព័ន្ធអ៊ីធឺណេត។ ដោយសារកត្តាសុខភាព និងជំងឺកូវីដ១៩កំពុងរាតត្បាត ម្តាយរបស់លោកបូជាចារ្យបុងបុងដែលមានអាយុ ៨២ឆ្នាំ មិនអាចមកចូលរួមបានឡើយ។

លោកបុងបុង ឲ្យដឹងថា គាត់សូមអរគុណដល់អ្នកម្តាយរបស់គាត់និងក្រុមសាច់ញាតិបងប្អូនរបស់គាត់ ដែលបានគាំទ្រខ្លាំងណាស់ចំពោះការត្រាស់ហៅជីវិតជាបូជាចារ្យរបស់គាត់។



លោកបុងបុង «ខ្ញុំបានប្រាប់ម្តាយថា បើគេហៅខ្ញុំធ្វើសច្ចាលើកចុងក្រោយ ប៉ុន្តែខ្ញុំត្រូវធ្វើនៅស្រុកខ្មែរ ...ម្តាយខ្ញុំថា តាមការសម្រេចចិត្តកូន អ្វីដែលសំខាន់កូនសប្បាយ ... គាត់នៅតែគាំទ្រ ហើយសប្បាយ សម្រាប់គាត់អត់ទាមទារសម្រាប់ខ្លួន គាត់អត់បានទាមទារសម្រាប់គ្រួសារ ដូច្នេះខ្ញុំអរគុណគ្រួសារខ្ញុំនៅហ្វីលីពីន។»

លោកបូជាចារ្យ បុង បុង បានថ្វាយពាក្យសច្ចានិរន្តរ៍ក្នុងក្រុមគ្រួសារសហជីវិនព្រះយេស៊ូ កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២២ នៅព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ (ពេទ្យយាយជី) ក្នុងខេត្តបាត់ដំបង ក្រោមអធិបតីភាពលោកអភិបាល ទេព ច័ន្ទពិសិទ្ធ (គីគេ) រួមជាមួយនិងលោកបូជាចារ្យមួយចំនួន និងគ្រីស្តបរិស័ទយ៉ាងច្រើនកុះករ។

ក្នុងបេសកកម្មក្នុងប្រទេសកម្ពុជារយៈពេលជិត១០ឆ្នាំមកនេះ លោកបូជាចារ្យបានថ្លែងថា ទោះបីជាកិច្ចការខ្លះ មានការពិបាក តែលោកពេញចិត្តនឹងការបម្រើដោយសេចក្តីស្រឡាញ់។ លោកបានបន្ថែមថា គ្រីស្តបរិស័ទនៅកម្ពុជាជាពិសេសភូមិភាគបាត់ដំបង បានបង្រៀន ជួយ និងផ្តល់កំលាំងដល់គាត់ឲ្យអាចបន្តដំណើរទៅមុខក្នុងជីវិតជាអ្នកបួស។

លោកបូជាចារ្យថ្វាយសច្ចានិរន្តរ៍បានបន្តថា សម្រាប់យុវជនដែលចង់ស្វែងរកការត្រាស់ហៅរបស់ខ្លួន ត្រូវមានជំនឿ សេចក្តីស្រឡាញ់ ហើយសូមរៀនឲ្យចប់សិន «ចំណេះដឹងគឺសំខាន់ណាស់ដើម្បីឲ្យការបម្រើអាចទៅមុខដោយស្រួល»។

លោកបានរំលឹកថា «ពេលខ្លះប្រធានយើងឲ្យរៀបចំអ្វីមួយតាមបច្ចេកទេស ខ្ញុំអត់ដែលស្គាល់សោះ តែដោយសារខ្ញុំធ្លាប់រៀន ធ្លាប់ស្រាវជ្រាវ ដូច្នេះ ខ្ញុំអាចទៅមុខ អាចបំពេញកិច្ចការងារនោះបានដោយរីករាយ។ ដូច្នេះ ចំណេះដឹងសំខាន់សម្រាប់ជីវិតជាបូជាចារ្យដែរ។»

ទោះបីជាយ៉ាងណាក្តី លោកបូជាចារ្យរូបនេះ បន្ថែមថា ការត្រាស់ហៅរបស់ព្រះជាម្ចាស់គឺសេចក្តីស្រឡាញ់ ដូច្នេះ បូជាចារ្យត្រូវទៅក្បែរយុវជន និងបង្ហាញជីវិតរបស់ខ្លួនដែលពោរពេញដោយអំណរសប្បាយ ដើម្បីឲ្យយុវជនទទួលអំណរសប្បាយនេះដែរ។

មានប្រសាសន៍នៅក្នុងធម្មទេសនានាឱកាសនោះ លោកបូជាចារ្យ តូតែត បាណោណាល់ បូជាចារ្យទទួលខុសត្រូវនៅព្រះវិហារសន្តយ៉ូហាន (សៀមរាប) ឲ្យដឹងថា ក្នុងថ្ងៃនេះ លោកឪពុកបុង បុង ធ្វើពាក្យសច្ចាចុងក្រោយ ហើយតាំងពីឥឡូវនេះ លោកឪពុកលែងមានអ្វីដែលអាចរារាំងផ្លូវដើម្បីប្រកាសព្រះរាជ្យរបស់ព្រះជាម្ចាស់ទៀតហើយ។ លោកឪពុករួមជាមួយសហជីវិនព្រះយេស៊ូ អាចបម្រើព្រះជាម្ចាស់ ព្រះសហគមន៍ និងបងប្អូនយ៉ាងពេញលក្ខណៈ។

លោកបូជាចារ្យតូតែតបានបញ្ជាក់ថា«លោកឪពុកបានសម្តែងជីវិតជាលោកឪពុកដ៏ល្អ សូមលោកឪពុកបន្តទៅមុខ។ សូមអរគុណលោកឪពុក អរគុណក្រុមគ្រួសារ អរគុណបងប្អូនទាំងអស់ដែលជួយហ្វឹកហ្វឺនលោកឪពុកឱ្យបានឈានទៅដល់ថ្ងៃនេះ។ សូមឱ្យពាក្យសច្ចារបស់លោកឪពុកបានក្លាយទៅជារូបរាងនៅក្នុងជីវិត ដើម្បីឱ្យយើងទាំងអស់គ្នាបានដើរជាផ្លូវតែមួយប្រកបដោយអំណរសប្បាយ ដែលមានលោកឪពុកនាំយើងទៅព្រះបិតាជាមួយព្រះយេស៊ូ។»

ក្នុងពិធីនោះដែរ លោកបូជាចារ្យបុងបុង បានចុះហត្ថលេខានិងប្រគល់ពាក្យសច្ចារបស់លោកជូនដល់លោកប្រធានក្រុមគ្រួសារនិងលោកអភិបាលព្រះសហគមន៍។ លោកបានប្រកាសថា នឹងយកជីវិតរស់នៅតាមសន្តអ៊ីញ៉ាស់ ជាអ្នកបង្កើតក្រុមគ្រួសារសហជីវិនព្រះយេស៊ូ ដោយរស់នៅជាព្រហ្មចារីធម៌ ស្តាប់បង្គាប់ និងរស់នៅបែបអ្នកក្រីក្រ ស្របតាមធម្មនុញ្ញរបស់ក្រុមគ្រួសារអ្នកបួសនេះ។

ក្នុងពិធីថ្វាយពាក្យសច្ចានិរន្តន៍ អង្គពិធីទាំងមូល បាននាំគ្នាលុតជង្គង់ ហើយព្រះសហគមន៍បានអង្វរដល់សន្តបុគ្គលទាំងឡាយ ឲ្យអង្វរព្រះជាម្ចាស់ដើម្បីបេសកកម្មនៃជីវិតជាអ្នកបួសរបស់លោកបូជាចារ្យបុងបុង ឲ្យកាន់តែមានអំណរសប្បាយក្នុងកិច្ចការប្រកាសដំណឹងល្អរបស់ព្រះយេស៊ូនៅលើផែនដីនេះ៕

## ព្រះវិហារសន្តយ៉ូសែបនិងជួងព្រះនាងម៉ារី ពោធិ៍បាន ...

*បន្តពីទំព័រ-១៤*

លោកអភិបាលក៏បានលាបប្រេងគ្រីស្មាលើតុអាសនៈ និងតាមជញ្ជាំងនានាផងដែរ ជាសញ្ញាមួយដែលបានភ្ជាប់ និងចូលរួមជាមួយព្រះជាម្ចាស់ផ្ទាល់។

លោកអភិបាល អូលីវីយេ មានប្រសាសន៍ថា ៖ «គ្រប់ពេលវេលាដែលយើងចូលវិហារនេះដើម្បីអធិដ្ឋាន យើងដឹងថាព្រះជាម្ចាស់មានឫទ្ធានុភាពដោយចេញពីជំនឿ និងពាក្យអធិដ្ឋាន។ ព្រះវិហារនៅកណ្តាលភូមិនេះ ដើម្បីឱ្យដឹងថាមានវត្តមានព្រះជាម្ចាស់»។

បច្ចុប្បន្ន ព្រះសហគមន៍ពោធិ៍បាន មានគ្រីស្តបរិស័ទ៦៤គ្រួសារ គឺប្រមាណជា២០០នាក់ និងមានសកម្មភាព ប្រកាសដំណឹងល្អដោយអប់រំជំនឿ សកម្មភាពមេត្តាករុណា និងផ្នែកអប់រំចំណេះទូទៅ មាន សាលាមត្តេយ្យ និងសាលាបឋមសិក្សាពីថ្នាក់ទី១ដល់ទី២។

ចំពោះថវិកាសាងសង់ព្រះវិហារ និងជើងជួងនេះ គឺបានមកពីការរៃអង្គាសប្រាក់ក្នុងព្រះសហគមន៍ដូចជា ពោធិ៍បាន ជ្រៃធំ កោះទាវ ស្អាង ទួលក្រសាំង បឹងឈូក តួតាំង ពោធិ៍ចិន តុង ចំប៉ា រួមនិងការបរិចាគពីលោកបូជាចារ្យក្នុងនិងក្រៅប្រទេស និងព្រះសហគមន៍មួយចំនួនពីប្រទេសវៀតណាម។ ថវិកាដែលប្រមូលបានមានចំនួន៤៩, ៥១១ដុល្លារអាមេរិក រីឯការសាងសង់ចំណាយអស់ទឹកប្រាក់៥១, ០១១ ដុល្លារអាមេរិក និងនៅខ្វះ១៥០០ដុល្លារអាមេរិកទៀត៕

# សកម្មភាពនានារបស់ព្រះសហគមន៍កាតូលិកកម្ពុជា

## ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ



សូមអធិដ្ឋានសម្រាប់វិញ្ញាណក្ខន្ធ
បងប្រុស Fransic Peter Amaoko Atta នៅក្នុង
ក្រុមបងប្រុសម៉ារីស នៅព្រះសហគមន៍កាតូលិកប៉ៃលិន។
បងប្រុសបានទទួលមរណភាពនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២។
សូមព្រះជាម្ចាស់ទទួលវិញ្ញាណក្ខន្ធបងប្រុស
ឱ្យរួមរស់ជាមួយព្រះអង្គអស់កល្បជានិច្ចផង។



## ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង



## ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម

